ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការគ្រប់គ្រងជ្រូកបំប៉នមួយក្បាល




រៀបចំដោយ **នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម**

សហការជាមួយ **នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល**

ឧបត្ថម្ភដោយ **គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី**

រៀបរៀងដោយ   លោក ម៉ារី ម៉ាឃ្លីន (Murray Maclean)

កាលបរិច្ឆេទ   ខែ កក្កដា ឆ្នាំ ២០០៦

© រក្សាសិទ្ធិគ្រប់យ៉ាង  គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះ ជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៏ អន្តរជាតិ (AusAID)តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹង ស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្មការ រៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលតាមរយៈការ វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង ។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបាន ឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមក ពីនាយកដ្ឋានជំនាញ នានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត ។ ឯកសារដ៏ មានសារៈសំខាន់នេះ គឺជាឯកសារ គោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាប ដល់ប្រជាកសិករ និង ផលិតករដែលរស់នៅក្នុងតំបន់មាន សក្តានុពលភាពស្របតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅ មូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការ ចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយ ភាពក្រីក្រស្របតាមយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រទទួលឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោល សម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យក ទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និង ទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម ។

**រដ្ឋមន្ត្រី**

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ "បទដ្ឋានអនុវត្តបច្ចេកវិទ្យា" ។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយ បញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់អោយមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រ កម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗ ទៀតដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៏កសិកម្ម នៅតាមមូលដ្ឋានប្រើប្រាស់ ។បអប មានលក្ខណៈដូចខាងក្រោមនេះ ៖-

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករ តាមរយៈ ប្រភព ជាច្រើន ដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗរបស់កសិករ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ននានាដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័ត និង អនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

DRAFT

# មាតិកា


**១. សេចក្តីអធិប្បាយ** ..... ១

**២. ការណែនាំបច្ចេកទេស** ..... ២

**២.១. សង្ខេបនៃការណែនាំបច្ចេកទេស** ..... ២

**២.២. ការកត់សំគាល់លើការណែនាំបច្ចេកទេស** ..... ២

*២.២.១ -ទិញកូនជ្រូកដែលមានសុខភាពល្អ និងបានកែលំអពូជរួច* ..... ២

*២.២.២-ផ្តល់កូនជ្រូកនូវស្នូកទឹក ចំណី និងទឹកដែលមានគុណភាពខ្ពស់* ..... ៤

*២.២.៣-ទិញចំណីពាណិជ្ជកម្មដែលមានប្រូតេអ៊ីន ៤០ភាគរយ ចំនួន១បាវដែលមានទម្ងន់ ៣០ គ.ក្រ ។ ផ្តល់ចំណីដល់កូន ជ្រូក ដោយល្បាយនៃចំណីដែលលាយផ្សំឡើងដោយចំណីពាណិជ្ជកម្ម ចុងអង្ករ និងកន្ទក់* ..... ៤

*២.២.៤- នៅពេលដែលចំណីផ្សំខាងលើអស់ ត្រូវផ្តល់ចំណីតាមបែបបុរាណវិញ ប៉ុន្តែត្រូវផ្តល់ចំណីតាមបែបបុរាណ នោះ រួមផ្សំទៅនឹងការផ្តល់ទឹកឱ្យបានគ្រប់គ្រាន់* ..... ១២

*២.២.៥- ស្នូកទឹកនិងចំណីត្រូវស្អាតជានិច្ច* ..... ១៣

*២.២.៦-ព្យាបាលកូនជ្រូកដោយ អ៊ីវឺម៉ិចទីន ក្នុងរយៈពេលដែលកូនជ្រូកស៊ីចំណី និង ផឹកទឹកបានច្រើន ។ ព្យាបាលកូន ជ្រូក ម្តងទៀតបន្ទាប់ពី១ខែក្រោយមក* ..... ១៣

*២.២.៧- ចាក់វ៉ាក់សាំងប៉េស្តិ៍ និង សាទឹក ដល់កូនជ្រូក ក្នុងរយៈពេល ២-៣ថ្ងៃ បន្ទាប់ពីការព្យាបាលប៉ារ៉ាស៊ីត* ..... ១៤

*២.២.៨- ហៅភ្នាក់ងារពេទ្យសត្វភូមិនៅពេលដែលកូនជ្រូកឈឺ* ..... ១៤

*២.២.៩- ធ្វើការលក់ដូរកូនជ្រូកឱ្យមានប្រសិទ្ធិភាព* ..... ១៤

**២.៣ ផលចំណេញផ្នែកសេដ្ឋកិច្ច** ..... ១៥

**៣. ការណែនាំលើការខារផ្សព្វផ្សាយ** ..... ១៧

**៣.១. ការរៀបចំស្ថាប័ន** ..... ១៧

**៣.២. ការធ្វើផែនការសកម្មភាព** ..... ១៨

**៣.៣ ឧបករណ៍ និង សំភារៈ** ..... ២២

**៣.៤ ថវិកាសម្រាប់ការធ្វើបង្ហាញ** ..... ២២

**៣.៥ ទីកន្លែងអនុវត្តន៍គម្រោង** ..... ២៤

**៤. ឧបសម្ព័ន្ធ** ..... ២៥

៤.១ ឧបសម្ព័ន្ធទី១. សៀវភៅរបាយការណ៍របស់អ្នកគ្រប់គ្រងស្រុក ..... ២៥

៤.២ ឧបសម្ព័ន្ធទី២. របាយការណ៍ជាគ្រឹះរបស់កសិករ ..... ២៨


DRAFT

៤.៣ ឧបសម្ព័ន្ធទី៣: របាយការណ៍របស់ភ្នាក់ងារពេទ្យសត្វភូមិ ........ ៣០
៤.៤ ឧបសម្ព័ន្ធទី៤: ខិត្តប័ណ្ណសម្រាប់ការយល់ដឹងអំពីការផ្តល់ចំណីដល់មេជ្រូក ........ ៣១
៤.៥ ឧបសម្ព័ន្ធទី៥: តារាងវាយតម្លៃទម្ងន់ជ្រូក ........ ៣២

DRAFT

## ១- សេចក្តីអធិប្បាយ

**ឈ្មោះអត្ថបទ** ការគ្រប់គ្រងជ្រូកបំប៉នមួយក្បាល

**ថ្ងៃ ខែ ឆ្នាំ:** ខែ មករា ឆ្នាំ ២០០៦

**ប្រភពបទដ្ឋានអនុវត្តន៍បច្ចេកវិទ្យា:** **Murray Maclean**

**ទិសដៅ និង ផលប្រយោជន៍:** ទិសដៅ

- ធ្វើឱ្យប្រសើរនូវចំណេះដឹង ជំនាញ និងប្រាក់ចំណូលដល់កសិករ ដែលចិញ្ចឹមជ្រូកមួយក្បាលតាមបែបបុរាណ តាមរយៈការផ្តល់ចំណីដែលបានកែលំអ និងការត្រួតពិនិត្យសុខភាព ។

កសិករក្រីក្រដែលចិញ្ចឹមជ្រូកបំប៉នមួយក្បាល ដោយធ្វើការផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រងការចិញ្ចឹមតាមបែបបុរាណ ទៅប្រព័ន្ធគ្រប់គ្រងការចិញ្ចឹមតាមការកែលំអ នឹងអាចកើនប្រាក់ចំណេញ (ពី ៥០.០០០ រៀល ទៅ ៨០.០០០ រៀល) ក្នុងជ្រូក ១ក្បាល និងកាត់បន្ថយរយៈពេលក្នុងការទទួលប្រាក់ចំណេញនេះ (ពី ៨ខែទៅ ៥ខែ)។ វានឹងថយចុះទ្វេរជាពីរនូវការប្រើប្រាស់កំលាំងពលកម្មជាប្រចាំថ្ងៃ។ ប្រព័ន្ធគ្រប់គ្រងតាមបែបកែលំអកាត់បន្ថយផងដែរនូវគ្រោះថ្នាក់ដែលបណ្តាលឱ្យស្លាប់ និងជម្ងឺផ្សេងៗដល់ជ្រូក ដោយសារការត្រួតពិនិត្យប៉ារ៉ាស៊ីត និងជម្ងឺឆ្លង។

វាមានការបង្កើននូវទំនាក់ទំនងរវាងជំនាញបច្ចេកទេស និងផ្សព្វផ្សាយក្នុងចំណោមស្ថាប័នដែលពាក់ព័ន្ធ ដូចជា ភ្នាក់ងារពេទ្យសត្វភូមិ មន្ត្រីបច្ចេកទេស និងផ្សព្វផ្សាយ និងអ្នកលក់ចំណីជ្រូកពាណិជ្ជកម្មតូចតាច។

**លក្ខខណ្ឌសមស្របទៅនឹងបច្ចេកទេស:** កសិករដែលចិញ្ចឹមជ្រូកបំប៉នមួយក្បាល មានចំនួនគ្រប់គ្រាន់តាមវិធីបុរាណ

**ការចូលទិន្នន័យសំខាន់ៗ**

- វត្តមាននៃភ្នាក់ងារពេទ្យសត្វភូមិ អាចជួយផ្តល់សេវាសុខភាព ហើយភ្នាក់ងារពេទ្យសត្វភូមិ អាចមានប្រសិទ្ធិភាពបានប្រសិនបើកសិករដឹង និងមានការជឿជាក់ចំពោះភ្នាក់ងារពេទ្យសត្វភូមិក្នុងការព្យាបាលសត្វឈឺ។ ការិយាល័យផលិតកម្ម និងបសុព្យាបាល និងអង្គការក្រៅរដ្ឋាភិបាលអាចជាប្រភពព័តិមាន ថាតើភ្នាក់ងារពេទ្យសត្វភូមិអាចមានប្រសិទ្ធិភាពរឺអត់ ។ការដើរមើលតាមភូមិ និងជួបជាមួយកសិករ និងភ្នាក់ងារពេទ្យសត្វភូមិ គឺជាមធ្យោបាយដ៏ល្អក្នុងការកំណត់ប្រសិទ្ធិភាពនៃភ្នាក់ងារពេទ្យសត្វ។
- មន្ត្រីពេទ្យសត្វស្រុកដែលមានប្រសិទ្ធិភាព ។
- ចំណីជ្រូកដែលមានលក្ខណៈពាណិជ្ជកម្ម ។

DRAFT

- ថ្នាំព្យាបាលប៉ារ៉ាស៊ីត និង វ៉ាក់សាំង ។

**ការចូលដល់ទីផ្សារ**

- តម្លៃជ្រូកក្នុងពេលបច្ចុប្បន្ន និងអនាគតកើនឡើងខ្ពស់កសិករគោលដៅដែលត្រូវបានជ្រើសរើស គឺជាកសិករដែលមានសភាពក្រីក្រ និងកំពុង ចិញ្ចឹមជ្រូកមួយក្បាល ។

កសិករត្រូវការថវិកាប្រហែល ៧២.០០០រៀល ដើម្បីទិញចំណីពាណិជ្ជកម្មចំនួន ១បាវដែលមានទម្ងន់ ៣០គ.ក្រ តម្លៃប្រហែល ៤០.០០០រៀល ដើម្បីទិញស្នូកពីរដែលមាំសម្រាប់ដាក់ចំណីនិងទឹក និងតម្លៃប្រហែល ៥.០០០រៀល សម្រាប់ទិញវ៉ាក់សាំងនិងថ្នាំព្យាបាល ។

# ២. ការណែនាំបច្ចេកទេស

## ២.១. សង្ខេបនៃការណែនាំបច្ចេកទេស

ក. ទិញកូនជ្រូកដែលមានសុខភាពល្អ និង បានកែលំអពូជរួច ។

ខ. ផ្តល់កូនជ្រូកនូវស្នូកទឹកចំណីនិងទឹកដែលមានគុណភាពខ្ពស់ ។

គ. ទិញចំណីពាណិជ្ជកម្មដែលមានប្រូតេអ៊ីន៤០ភាគរយ ចំនួន១បាវដែលមានទម្ងន់ ៣០គ.ក្រ។ ផ្តល់ចំណីដល់កូនជ្រូកដោយល្បាយនៃចំណីដែលលាយផ្សំឡើងដោយចំណីពាណិជ្ជកម្ម ចុងអង្ករ និង កន្ទក់ ។

ឃ. នៅពេលដែលចំណីផ្សំខាងលើអស់ ត្រូវផ្តល់ចំណីតាមបែបបុរាណវិញ ប៉ុន្តែត្រូវផ្តល់ចំណីតាមបែបបុរាណនោះរួមផ្សំទៅនឹងការផ្តល់ទឹកឱ្យបានគ្រប់គ្រាន់ ។

ង. ស្នូកទឹកនិងចំណីត្រូវស្អាតជានិច្ច ។

ច. ព្យាបាលកូនជ្រូកដោយ អ៊ីវឺម៉ិចទីន ក្នុងរយៈពេលដែលកូនជ្រូកស៊ីចំណី និង ផឹកទឹកបានច្រើន ។ ព្យាបាលកូនជ្រូកម្តងទៀតបន្ទាប់ពី១ខែក្រោយមក ។

ឆ. ចាក់វ៉ាក់សាំងប៉េស្ត៍ និង សាទឹក ដល់កូនជ្រូក ក្នុងរយៈពេល ២-៣ថ្ងៃ បន្ទាប់ពីការព្យាបាលប៉ារ៉ាស៊ីត

ជ. ហៅភ្នាក់ងារពេទ្យសត្វភូមិនៅពេលដែលកូនជ្រូកឈឺ ។

ឈ. ធ្វើការលក់ដូរកូនជ្រូកឱ្យមានប្រសិទ្ធិភាព ។

## ២.២. ការកត់សំគាល់លើការណែនាំបច្ចេកទេស

### ២.២.១ -ទិញកូនជ្រូកដែលមានសុខភាពល្អ និងបានកែលំអពូជរួច

កូនជ្រូកជាច្រើនដែលបានលក់ដូរនៅក្នុងប្រទេសកម្ពុជា ពុំមានសុខភាពល្អពីព្រោះ

- កូនជ្រូកពុំទាន់រីកលូតលាស់បានល្អ និង មានស្ត្រេស (Stress) យ៉ាងច្រើនក្នុងកំឡុងពេលដែលកំពុងបៅដោះ ដោយសារតែមេជ្រូកជាទូទៅត្រូវបានផ្តល់នូវចំណី និងទឹកដែលមានគុណភាពនិងបរិមាណទាប ហើយមេជ្រូកជាទូទៅពុំបានព្យាបាលប៉ារ៉ាស៊ីត។ កូនជ្រូកជាទូទៅមានទម្ងន់ ៤-៥ គ.ក្រ នៅពេលផ្តាច់ដោះ។

- កូនជ្រូកមានស្ត្រេស (Stress) ក្នុងពេលធ្វើការលក់ដូរ គឺដោយសារកូនជ្រូកជាញឹកញាប់ត្រូវបានដាក់ក្នុងជុចឫស្សី ចង្អៀត ដែលដឹកនៅពីក្រោយម៉ូតូ និងធ្វើដំណើរឆ្ងាយដោយគ្មានដាក់ទឹកនិងចំណី។ នៅក្រោមលក្ខខណ្ឌនេះ កូនជ្រូកបាត់បង់ ជាតិទឹកយ៉ាងលឿន ដោយសារវានៅតូច និងកូនជ្រូកអាចទទួលជម្ងឺដូចជា ប៉េស្ត៍។
- ការផ្តាច់ដោះភ្លាមៗ និងមិនបង្រៀនឱ្យកូនជ្រូកស៊ីចំណីមុនពេលផ្តាច់ដោះ។

ជ្រូកភាគច្រើននៅតាមភូមិនៃប្រទេសកម្ពុជា គឺមានពូជដែលបានមកពីល្បាយនៃពូជផ្សេងៗគ្នាដូចជា ពូជដើមក្នុងស្រុក ឡេនដ្រេស យ៉កស្សៀរ ហៃណាំ។ ពូជជ្រូក ឌុរ៉ុក គឺទើបតែនាំចូលថ្មីៗនេះទេ ហើយដែលអាចឃើញនៅតាមតំបន់ខ្លះ។ ពូជជ្រូកក្នុងស្រុកដែលមានពណ៌ខ្មៅ និងមានការលូតលាស់យឺត ពុំគួរត្រូវបានជ្រើសរើសដើម្បីផ្តល់ចំណីបែបពាណិជ្ជកម្មឡើយ។

ជ្រូកដែលបានពីការបង្កាត់រវាងពូជផ្សេងៗ គឺគួរជ្រើសរើសសម្រាប់កម្មវិធីគ្រប់គ្រងដែលមានការកែលំអ។ ជ្រូកទាំងនេះ អាចឆ្លើយតបទៅនឹងចំណីដែលមានគុណភាពខ្ពស់ និងត្រូវបានជំរុញសម្រាប់អនុវត្តន៍នៅក្នុង (បទដ្ឋានអនុវត្តបច្ចេកវិទ្យា)នេះ។

កសិករដែលទិញកូនជ្រូកមួយក្បាលសម្រាប់បំប៉នគួរព្យាយាម:

- ទិញកូនជ្រូកដោយផ្ទាល់ពីកសិដ្ឋានដែលចិញ្ចឹមជ្រូកសម្រាប់លក់កូន។ កូនជ្រូកអាចត្រូវបានទិញក្នុងពេលដែល វាកំពុងបៅ ប៉ុន្តែគួរទិញកូនជ្រូកនៅពេលផ្តាច់ដោះបានយ៉ាងហោចណាស់ ២-៣ថ្ងៃ។ ជាការប្រសើរបំផុត គឺគួរទិញកូនជ្រូកដែលមេរបស់វាត្រូវបានចាក់វ៉ាក់សាំង និងព្យាបាលប៉ារ៉ាស៊ីតដោយទៀងទាត់។
- ទិញកូនជ្រូកដែលមេរបស់វាត្រូវបានផ្តល់ចំណីគ្រប់គ្រាន់ និង ព្យាបាលប៉ារ៉ាស៊ីត និងចាក់វ៉ាក់សាំងរួច។
- ទិញកូនជ្រូកដែលមានទម្ងន់ប្រហែល ៧-៨ គ.ក្រ ក្នុងអាយុ ៥-៦ សប្តាហ៍ មានសភាពខ្លាំងក្លា និង មាន រូបរាងល្អ ។
- ទិញកូនជ្រូកដែលបានក្រៀវរួចប្រសិនបើឈ្មោល ពីព្រោះការក្រៀវកូនជ្រូកបន្ទាប់ពីផ្តាច់ដោះរយៈពេលយូរ នឹងបណ្តាលឱ្យមានស្ត្រេស និងបាត់បង់ទម្ងន់ដល់កូនជ្រូក។






**កសិករជាច្រើន ទិញកូនជ្រូកពីអ្នកលក់ដែលដាក់កូនជ្រូកយ៉ាងច្រើនក្នុងជុចឫស្សី ដោយដឹកតាមម៉ូតូ។**

**ជាការល្អ កសិករគួរទិញកូនជ្រូកពីកន្លែងមេដោយផ្ទាល់**

តម្លៃកូនជ្រូកអាចប្រែប្រួលទៅតាមពូជ ទម្ងន់ ការវាយតម្លៃសុខភាព និងតម្លៃសាច់ជ្រូកក្នុងពេលបច្ចុប្បន្ន និងអនាគត។ តាមការណែនាំទូទៅ តម្លៃជាមធ្យមរបស់កូនជ្រូកក្នុង ១គ.ក្រ នៃទម្ងន់ស្រស់របស់កូនជ្រូក គឺស្មើពីរដង នៃតម្លៃក្នុង ១គ.ក្រ នៃទម្ងន់ស្រស់របស់ជ្រូកធំនៅពេលលក់។ ឧទាហរណ៍: ប្រសិនបើតម្លៃក្នុង ១គ.ក្រ នៃទម្ងន់ជ្រូកស្រស់ដែលលក់ថ្លៃ ៥.០០០ រៀល នោះតម្លៃកូនជ្រូកនឹងថ្លៃ ១០.០០០ រៀល ។

### ២.២.២-ផ្តល់កូនជ្រូកនូវស្នូកទឹក ចំណី និងទឹកដែលមានគុណភាពខ្ពស់

កូនជ្រូកដែលចិញ្ចឹមតាមបែបបុរាណ ជាទូទៅត្រូវបានទទួលស្នូកទឹកនិងចំណីរួមគ្នាដែលធ្វើអំពីឈើ ហើយដែលស្នូកទាំងនេះងាយស្រួលដួល រឺ កំពប់ ។

កសិករគួរផ្តល់ស្នូកពីរដាច់ដោយឡែកពីគ្នាដែលមានទំហំធំល្មម និងសភាពមាំ ដើម្បីឱ្យកូនជ្រូកងាយស្រួលស៊ីចំណី និង ផឹកទឹក។







**តាមការចិញ្ចឹមតាមបែបបុរាណ កូនជ្រូកអាចទទួលបាននូវស្នូកទឹកចំណីតែមួយគត់ដែលមានទម្ងន់ស្រាលហើយងាយស្រួលដួល រឺ កំពប់។ កូនជ្រូកគួរមានស្នូក ពីរធុង់ៗ គឺមួយសម្រាប់ដាក់ចំណី និង មួយទៀតសម្រាប់ដាក់ទឹក។**

### ២.២.៣-ទិញចំណីពាណិជ្ជកម្មដែលមានប្រូតេអ៊ីន ៤០ភាគរយ ចំនួន១បាវដែលមានទម្ងន់ ៣០ គ.ក្រ។ ផ្តល់ចំណីដល់កូនជ្រូក ដោយល្បាយនៃចំណីដែលលាយផ្សំឡើងដោយចំណីពាណិជ្ជកម្ម ចុងអង្ករ និងកន្ទក់

**ការណែនាំលើការផ្តល់ចំណី និង ការលូតលាស់របស់ជ្រូក:**

នៅក្រោមលក្ខខណ្ឌការចិញ្ចឹមតាមភូមិ ជ្រូកបំប៉នដែលត្រូវបានគ្រប់គ្រង និងផ្តល់ចំណីបានត្រឹមត្រូវ ចាប់ពីពេលផ្តាច់ដោះ រហូតដល់ពេលពិឃាដ ជាទូទៅមានទម្ងន់ ៩០គ.ក្រ ក្នុងរយៈពេល ១៥០ថ្ងៃ ហើយគំរូនៃការកើនឡើងនូវទម្ងន់ ស្រស់ត្រូវបានបង្ហាញក្នុងក្រាហ្វិកខាងក្រោម:

ក្រាហ្វិកទី១ ការធំធាត់របស់ជ្រូកនៅក្រោមប្រព័ន្ធគ្រប់គ្រងដោយមានការកែលំអកំរិតខ្ពស់




គំរូនៃការធំធាត់របស់ជ្រូកខាងលើនេះអាចត្រូវបានចែកជា ៤ ដំណាក់កាល ដែលក្នុងនោះជ្រូកផលិតបរិមាណផ្សេងៗគ្នានៃឆ្អឹង សាច់ និងខ្លាញ់។ ដំណាក់កាលទាំងនោះមាន:

- នៅដំណាក់កាលទី១ អត្រានៃការលូតលាស់របស់ជ្រូក (គ.ក្រ ក្នុង១ថ្ងៃ) ទាប ប៉ុន្តែមានការកើនឡើង។ ក្នុងតំណាក់កាលនេះ កូនជ្រូកអាចមានការលូតលាស់ឆ្អឹង និងសាច់យ៉ាងខ្លាំង ប៉ុន្តែមានការផលិតខ្លាញ់តិច ដូចសមាមាត្រនៃការលូតលាស់សរុប ។
- នៅដំណាក់កាលទី២ អត្រានៃការលូតលាស់របស់ជ្រូកទាប ប៉ុន្តែមានការកើនឡើង។ ក្នុងតំណាក់កាលនេះ កូនជ្រូកអាចមានការលូតលាស់ឆ្អឹង និងសាច់មានសភាពខ្លាំងល្មម ប៉ុន្តែមានការផលិតខ្លាញ់តិច ដូចសមាមាត្រនៃការលូតលាស់សរុប។
- នៅដំណាក់កាលទី៣ អត្រានៃការលូតលាស់របស់ជ្រូកខ្ពស់ខ្លាំង។ កូនជ្រូកអាចមានការលូតលាស់ឆ្អឹងមធ្យម ការលូតលាស់សាច់ខ្ពស់ និងការផលិតខ្លាញ់ជាមធ្យម ដូចសមាមាត្រនៃការលូតលាស់សរុប។
- នៅដំណាក់កាលចុងក្រោយ: អត្រានៃការលូតលាស់របស់ជ្រូកខ្ពស់ខ្លាំងម្តងទៀត។ ជ្រូកអាចមានការលូតលាស់ឆ្អឹងតិចតួច ការលូតលាស់សាច់ជាមធ្យម និងការផលិតខ្លាញ់ខ្ពស់ដូចសមាមាត្រនៃការលូតលាស់សរុប។

អត្រានៃការលូតលាស់ជាមធ្យមក្នុងដំណាក់កាលផ្សេងៗគ្នា និងការផលិតឆ្អឹង សាច់ និងខ្លាញ់ ត្រូវបានបង្ហាញក្នុងតារាងដូចខាងក្រោម:

DRAFT

តារាងទី១. អត្រាធំធាត់ជាមធ្យម និង សមាសភាពនៃការធំធាត់របស់ជ្រូកដែលចិញ្ចឹមដោយមានការកែលំអ

| ដំណាក់កាលនៃការលូតលាស់ | ទម្ងន់ជ្រូក (គ.ក្រ) | រយៈពេល (ថ្ងៃ) | កំណើនទម្ងន់ជាមធ្យម (គ.ក្រ/១ថ្ងៃ) | ការផលិតឆ្អឹង | ការផលិតសាច់ | ការផលិតខ្លាញ់ |
|---|---|---|---|---|---|---|
| ទី១ | ៧-២០ | ៥០ | ០,២៦ | ខ្ពស់ខ្លាំង | ខ្ពស់ខ្លាំង | ទាប |
| ទី២ | ២០-៤០ | ៤០ | ០,៥០ | ខ្ពស់ | ខ្ពស់ | ទាប |
| ទី៣ | ៤០-៦០ | ២៧ | ០,៧៤ | មធ្យម | ខ្ពស់ | មធ្យម |
| ទី៤ | ៦០-៩០ | ៣៣ | ០,៩១ | ទាប | ទាប | ខ្ពស់ |

ចំនួនចំណីដែលជ្រូកស៊ី មានការកើនឡើងដូចដែលជ្រូកមានការលូតលាស់។ ជ្រូកតូចៗមានក្រពះតូច និងជ្រូកធំៗមានក្រពះធំ។ តារាងខាងក្រោមបង្ហាញពីចំនួនចំណីជ្រូកដែលជ្រូកស៊ីក្នុង១ថ្ងៃ ដែលគិតទៅតាមទម្ងន់របស់វា។ ចំនួនចំណីជ្រូកនេះ វាមានការខុសគ្នាយ៉ាងខ្លាំងពីជ្រូកមួយទៅជ្រូកមួយទៀត ហើយគួរត្រូវបានប្រើប្រាស់ជាការណែនាំប៉ុណ្ណោះ។ វាមានសារៈសំខាន់ណាស់ក្នុងការចងចាំដែរថា សម្រាប់ការលូតលាស់អតិបរមា យើងគួរផ្តល់ចំណីជ្រូកឱ្យបានច្រើន ។

តារាងទី២. ការណែនាំដល់ការស៊ីចំណីរបស់ជ្រូក

| **ទម្ងន់ជ្រូក (គ.ក្រ)** | **ការស៊ីចំណី (គ.ក្រ)** | **ទម្ងន់ជ្រូក (គ.ក្រ)** | **ការស៊ីចំណី (គ.ក្រ)** | **ទម្ងន់ជ្រូក (គ.ក្រ)** | **ការស៊ីចំណី (គ.ក្រ)** |
|---|---|---|---|---|---|
| ៥ | ០,៣ | ៣៥ | ១,៧ | ៦៥ | ២,៦ |
| ១០ | ០.៥ | ៤០ | ១,៩ | ៧០ | ២,៨ |
| ១៥ | ០.៨ | ៤៥ | ២,០ | ៧៥ | ២,៩ |
| ២០ | ១.០ | ៥០ | ២,២ | ៨០ | ៣,០ |
| ២៥ | ១.៣ | ៥៥ | ២,៤ | ៨៥ | ៣,០ |
| ៣០ | ១.៥ | ៦០ | ២,៥ | ៩០ | ៣,១ |

DRAFT

ដើម្បីសំរេចការលូតលាស់អតិបរមា ជ្រូកត្រូវស៊ីចំណីឱ្យបានសមស្របទៅនឹងការឃ្លានចំណីរបស់វា នៅតាមដំណាក់កាលនីមួយៗ និងប្រភេទនៃការផលិតសាច់ ខ្លាញ់ រឺ ឆ្អឹង។ ចំពោះសត្វជ្រូក ប្រូតេអ៊ីនត្រូវបានប្រើប្រាស់សម្រាប់ផលិតសាច់ ថាមពល ត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពប្រចាំថ្ងៃ និងផលិតខ្លាញ់ និងសារធាតុរ៉ែ គឺសម្រាប់ប្រើប្រាស់ក្នុងការផលិតឆ្អឹង។ សម្រាប់ហេតុផលនេះ

- ជ្រូកដែលនៅតូចគួរស៊ីចំណីដែលមានប្រូតេអ៊ីន ថាមពល និងសារធាតុរ៉ែ (សម្រាប់ការលូតលាស់ឆ្អឹង) ខ្ពស់ និងចំណីដែលមានជាតិសរសៃតិច (ព្រោះប្រព័ន្ធរំលាយអាហាររបស់ជ្រូកមិនអាចរំលាយជាតិសសៃដោយងាយស្រួលទេ)។
- ជ្រូកដែលមានទំហំធំល្មម គួរស៊ីចំណីដែលមានប្រូតេអ៊ីន ថាមពល និងសារធាតុរ៉ែមិនសូវខ្ពស់ ប៉ុន្តែជាតិសរសៃល្មម។
- ជ្រូកដែលធំគួរស៊ីចំណីដែលមានប្រូតេអ៊ីន ថាមពល និង សារធាតុរ៉ែទាប ប៉ុន្តែជាតិសសៃខ្ពស់។

ទឹកក៏មានសារៈសំខាន់ផងដែរ ជាពិសេសសម្រាប់ជ្រូកតូចៗ។ នៅពេលកូនជ្រូកដែលទើបនឹងកើត គឺប្រហែល ៨០ភាគរយ នៃទម្ងន់របស់វាគឺជាទឹក។ នៅពេលដែលវាមានអាយុច្រើន ភាគរយទឹកមានការថយចុះ។ នៅពេលដែលវាមានទម្ងន់ ១០០គ.ក្រ រូបរាង្គកាយរបស់វានឹងមានទឹក ៦០គ.គ្រ (គឺថា ៦០ ភាគរយ)។ ហេតុដូច្នេះហើយតាមច្បាប់ទូទៅ ជ្រូកត្រូវផឹកទឹកចំនួន ៣លីត្រ សម្រាប់សមាមាត្រ នឹង ១គ.ក្រ នៃចំណីស្ងួតដែលវាស៊ី។

ជ្រូកត្រូវទទួលវីតាមីនជាច្រើនប្រភេទផងដែរ ដើម្បីតម្រូវឱ្យជ្រូកមានការលូតលាស់លឿន។

**ប្រភេទនៃចំណីជ្រូកៈ**

ត្រី ម្សៅត្រី សណ្តែកសៀង ម្សៅសណ្តែកសៀង ម្សៅសណ្តែកដី មានប្រូតេអ៊ីនខ្ពស់។ ផ្នែកនៃរុក្ខជាតិខ្លះមានប្រូតេអ៊ីន មធ្យម ដូចជាត្រកួន ស្លឹកកន្ទំថេត ស្លឹក Stylo និងស្លឹកដំឡូងមី។ ផលិតផលត្រី ក៏សំបូរដោយជាតិរ៉ែផងដែរ។ ចំណីទាំងនេះ+

- អាចប្រមូល និងកែច្នៃដោយកសិករដោយខ្លួនឯង។ វិធីនេះចំណាយពេលកម្មខ្ពស់សម្រាប់កសិករ ប៉ុន្តែចំណាយប្រាក់តិច។ គុណភាពនៃចំណីដែលរកតាមវិធីនេះ មិនត្រូវបានធានាឡើយ។
- ត្រូវបានទិញដោយក្រុមហ៊ុនដោយលាយវាជាមួយសារធាតុរ៉ែ និងវីតាមីន ហើយដាក់ចូលក្នុងស្បោង រួចលក់ទៅអោយកសិករ។ ក្រុមហ៊ុនជាធម្មតាទិញ និងលាយ ម្សៅសណ្តែកសៀង ម្សៅត្រី និងម្សៅសណ្តែកដី ជាមួយគ្នា។

វាមានចំណីបែបពាណិជ្ជកម្មគ្រប់បែបយ៉ាងដែលផលិតដោយក្រុមហ៊ុនផ្សេងៗគ្នាអាចរកបាននៅតាមតូប រឺ ហាងតូចៗ នៅគ្រប់ខេត្ត និងស្រុកនៃប្រទេសកម្ពុជា។ ចំណីបែបពាណិជ្ជកម្មត្រូវបានៈ

- នាំចូលពីប្រទេសថៃ ដែលនៅលើថង់នោះត្រូវបានសរសេរជាភាសាថៃ ។
- នាំចូលពីប្រទេសវៀតណាម ដែលនៅលើថង់នោះត្រូវបានសរសេរជាភាសាវៀតណាម។
- ផលិតដោយក្រុមហ៊ុន ស៊ី ភី នៅក្នុងខេត្តកំពង់ស្ពឺ។

DRAFT







វាមានចំណីជ្រូកបែបពាណិជ្ជកម្មជាច្រើនប្រភេទអាចរកបាននៅប្រទេសកម្ពុជា ។ ចំណីទាំងអស់នេះផលិតនៅក្នុងប្រទេសកម្ពុជា វៀតណាម រឺ ថៃ ដែលមានផ្លាកសញ្ញា ជាភាសាខ្មែរ វៀតណាម រឺ ថៃ ។ ចំណីទាំងអស់នេះធ្វើឱ្យអ្នកលក់ និង កសិករ មានការលំបាកក្នុងការប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព ។

ចំណីបែបពាណិជ្ជកម្ម ត្រូវបានផលិតដោយច្រកថង់តាមទំហំផ្សេងៗគ្នាដែលនៅក្នុងនោះកំរិតនៃជាតិប្រូតេអ៊ីន ថាមពល និងរ៉ែ ត្រូវបានផ្សំឡើងខុសៗគ្នាដើម្បីតម្រូវទៅតាមស្ថានភាពនៃការផ្តល់ចំណី ។ ជាធម្មតា ចំណីត្រូវបានផលិតឡើងដោយផ្សំលាយនូវម្សៅសណ្តែកសៀង ម្សៅត្រី ពោត និង រ៉ែ និង បន្ថែមពពួកវីតាមីន ។ ជាទូទៅ ចំណីមានពីរប្រភេទៈ

- ចំណីផ្សំត្រូវបានផ្តល់ទៅឱ្យជ្រូកទាំងស្រុង
- ចំណីផ្សំដែលមានប្រូតេអ៊ីនខ្ពស់ (៤០ភាគរយ) ត្រូវបានលាយជាមួយចំណីដែលមានប្រូតេអ៊ីនទាបដូចជា ចុងអង្ករ កន្ទក់ រឺ ពោត ។ ក្នុងករណីនេះ អត្រាលាយនៃចំណីនោះជាទូទៅត្រូវបានសរសេរនៅលើថង់ ។

វាមានការពិបាកសម្រាប់កសិករក្នុងការប្រើប្រាស់ចំណីបែបពាណិជ្ជកម្មឱ្យបានត្រឹមត្រូវព្រោះៈ

- ការណែនាំអំពីការប្រើប្រាស់នៃការផ្តល់ចំណីត្រូវបានសរសេរជាភាសាថៃ រឺ វៀតណាម
- អ្នកលក់មិនបានយល់អំពីចំណីផ្សេងៗ និង របៀបប្រើប្រាស់របស់វាឱ្យបានត្រឹមត្រូវ ។ ដូច្នេះពួកគេមិនអាចផ្តល់តំបូន្មានដល់កសិករ ។

DRAFT

តារាងទី៣. គំរូខ្លះនៃចំណីពាណិជ្ជកម្មដែលមានប្រូតេអ៊ីនខ្ពស់

| គំរូខ្លះនៃចំណីពាណិជ្ជកម្មដែលមានប្រូតេអ៊ីនខ្ពស់ | | | | | |
|---|---|---|---|---|---|
| ឈ្មោះចំណី | ប្រូតេអ៊ីន | ទំហំថង់ | ក្រុមហ៊ុន | តម្លៃក្នុង១ថង់ | តម្លៃក្នុង១គ.ក្រ |
| Hi-Gro 151 | ៣៦% | ៥ គ.ក្រ | ស៊ីភី | ១១០០០ | ២២០០ |
| Hi-Gro 156 | ៣២% | ៥ គ.ក្រ | ស៊ីភី | ១១០០០ | ២២០០ |
| Beta Gro 209 | ៣៦% | ៥ គ.ក្រ | ថៃ | ១២០០០ | ២៤០០ |
| Beta Gro 74A | ៤០% | ៥ គ.ក្រ | ថៃ | ១៣០០០ | ២៦០០ |
| Beta Gro 226 | ៣៤% | ៥ គ.ក្រ | ថៃ | ១២០០០ | ២៤០០ |

ចុងអង្ករ និងពោត មានថាមពលខ្ពស់ និងប្រូតេអ៊ីនទាប។ ចុងអង្ករលេខ២ មានថាមពល និងប្រូតេអ៊ីនទាប ប៉ុន្តែមានជាតិសរសៃខ្ពស់។ ចុងអង្ករលេខ២ មានជាតិសរសៃខ្ពស់ជាងចុងអង្ករលេខ៣។ នៅក្នុងប្រទេសកម្ពុជា ចុងអង្ករ និងកន្ទក់អាចរកបាន ប៉ុន្តែពោតជាទូទៅមិនអាចរកបានទេ។

**ការផ្តល់ចំណីតាមបែបធម្មជាតិដល់ជ្រូកបំប៉ន៖**

នៅប្រទេសកម្ពុជាកសិករក្រីក្រដែលចិញ្ចឹមជ្រូកមួយក្បាលដោយចងនៅក្រោមផ្ទះ បានផ្តល់ចំណីដែលមានគុណភាព និងបរិមាណទាប។ របបចំណីភាគច្រើនគឺ កន្ទក់លាយជាមួយបបរដែលបានចំអិន ព្រមទាំងត្រកួនដែលបានទិញ រឺ ប្រមូលក្នុងរដូវភ្លៀង ដែលបន្ថែមទៅលើកាកសំណល់ផ្ទះបាយ។ ពេលខ្លះ ក្បាលត្រីអាចផ្តល់ជាចំណីផងដែរ។ របបចំណីនេះត្រូវបាន ផ្តល់ជាទូទៅ១ថ្ងៃ៣ដង។ កសិករមិនបានប*្ត្បូរចំណី និងប្តូរគុណភាព និងបរិមាណនៃចំណីក្នុងរយៈពេលនៃការលូតលាស់របស់ជ្រូក ព្រោះរយៈពេលនេះ វាត្រូវការប្តូរនូវតំរូវនៃការលូតលាស់ និង សក្តានុពលនៃការស៊ីចំណី។

នៅក្នុងប្រព័ន្ធគ្រប់គ្រងដោយមានការកែលំអកំរិតទាបនេះ កូនជ្រូកមានការធំធាត់យឺត គឺមានទម្ងន់អាចដល់ ៩០គ.ក្រ ក្នុងអាយុប្រហែល ១១ខែ។ ទោះបីជាយ៉ាងណាក៏ដោយ ទម្ងន់នេះមានការប្រែប្រួលយ៉ាងខ្លាំងដោយសារពូជ ចំណី និង សុខភាព។ លើសពីនេះទៅទៀត ជ្រូកដែលលក់ភាគច្រើនមានខ្លាញ់ច្រើន និង សាច់តិច។

ក្រាហ្វិកខាងក្រោម បង្ហាញពីការប្រែប្រួលនៃទម្ងន់នៅក្រោមប្រព័ន្ធគ្រប់គ្រងដោយមានការកែលំអកំរិតខ្ពស់ និងទាប។ ក្នុងឧទាហរណ៍នេះ ជ្រូកចិញ្ចឹមនៅក្រោមប្រព័ន្ធគ្រប់គ្រងដោយមានការកែលំអកំរិតទាបមានទម្ងន់អាចដល់ ៩០គ.ក្រ ក្នុងរយៈពេល ១១ខែ។

ក្រាហ្វិកទី២០: ការធំធាត់របស់ជ្រូកនៅក្រោមប្រព័ន្ធគ្រប់គ្រងដោយមានការកែលំអកំរិតខ្ពស់ និង ទាប




ក្នុងការបំប៉នជ្រូកតាមបែបបុរាណ ចំណីរបស់វាមានប្រូតេអ៊ីន និង ថាមពលទាប។ ជាលទ្ធផល ជ្រូកផលិតសាច់តិច នៅពេលជ្រូកនៅតូច និង ផលិតខ្លាញ់ច្រើននៅពេលជ្រូកមានទំហំធំ ជាពិសេសនៅពេលជ្រូកមានទម្ងន់លើសពី ៧០គ.ក្រ។





**ជ្រូកដែលចិញ្ចឹមនៅក្រោមប្រព័ន្ធគ្រប់គ្រង ដោយមានការកែលំអកំរិតខ្ពស់ ដូចជាជ្រូកក្នុងរូបនេះដែលបានថតនៅខេត្តព្រៃវែង អាចមានទម្ងន់ ៩០ គ.ក្រ បន្ទាប់ពីមានអាយុ ១៥០ ថ្ងៃ ។ ជ្រូកទាំងនេះមានសាច់ច្រើន និង ខ្លាញ់តិច ហើយអាចមានតម្លៃ ខ្ពស់ជាងជ្រូកដែលមានសាច់តិច និង ខ្លាញ់ច្រើន ។**

**ការផ្តល់ចំណីតាមបែបប្រព័ន្ធដែលមានការលំអកំរិតខ្ពស់ដល់ជ្រូកដែលមានអាយុតិចៈ**

“បទដ្ឋានអនុវត្តបច្ចេកវិទ្យា” នេះ បង្ហាញពីការផ្តល់ចំណីដល់កូនជ្រូកដែលមានអាយុតិច ហើយយុទ្ធសាស្ត្រនេះនឹងផ្តល់ផលចំណេញមកវិញលើការវិនិយោគនៃប្រាក់ដែលមានកំណត់ ។

កសិករៈ

- ទិញចំណីប្រូតេអ៊ីនផ្សំតាមបែបពាណិជ្ជកម្ម ១បាវដែលមានទម្ងន់ ៣០គ.ក្រ ជាការល្អ (ប្រូតេអ៊ីនមាន ៤០ភាគរយ) ដែលមានតម្លៃ ៧២០០០រៀល ។
- លាយចំណីពាណិជ្ជកម្មនោះ ១០គ.ក្រ ជាមួយកន្ទក់ ៥គ.ក្រ និងចុងអង្ករ ១០គ.ក្រ រួចផ្តល់ឱ្យកូនជ្រូករហូត ដល់ចំណីដែលលាយនោះអស់ ។
- លាយចំណីពាណិជ្ជកម្មដែលនៅសេសសល់ ២០គ.ក្រ ជាមួយកន្ទក់ ២០គ.ក្រ និង ចុងអង្ករ ២០គ.ក្រ ។

តារាងខាងក្រោមបង្ហាញពីការណែនាំនូវការលាយចំណី ដែលនៅក្នុងនោះចំណីពាណិជ្ជកម្មចំនួន ៥គ.ក្រ ត្រូវបានលាយតែមួយដង ។

DRAFT

តារាងទី៤. ការណែនាំនូវការលាយចំណី

| ការណែនាំនូវការលាយចំណី | | | |
|---|---|---|---|
| ថ្ងៃដែលបានលាយ | ចំណីពាណិជ្ជកម្ម (គ.ក្រ) | កន្ទក់ (គ.ក្រ) | ចុងអង្ករ (គ.ក្រ) |
| ការលាយលើកទី១ | ៥ | ២,៥ | ៥ |
| ការលាយលើកទី២ | ៥ | ២,៥ | ៥ |
| ការលាយលើកទី៣ | ៥ | ៥ | ៥ |
| ការលាយលើកទី៤ | ៥ | ៥ | ៥ |
| ការលាយលើកទី៥ | ៥ | ៥ | ៥ |
| ការលាយលើកទី៦ | ៥ | ៥ | ៥ |
| **សរុប** | **៣០** | **២៥** | **៣០** |

កសិករគួរត្រួតពិនិត្យទម្ងន់ជ្រូករបស់ពួកគេ ដោយប្រើប្រាស់ជញ្ជីងថ្លឹងប្រសិនបើពួកគេមាន។ ប្រសិនបើគ្មានជញ្ជីងថ្លឹង កសិករអាចប៉ាន់ស្មានទម្ងន់ជ្រូករបស់ពួកគេដោយប្រើប្រាស់ខ្សែវាស់។ ដើម្បីវាស់បាន កសិករគួរចងជ្រូក រួចវាស់ពីផ្នែកខាងលើនៃក្បាលជ្រូករហូតដល់កន្ទុយ បន្ទាប់មកវាស់ជុំវិញទទឹងជ្រូក។ រូបមន្តខាងក្រោមត្រូវបានគេប្រើប្រាស់សម្រាប់គណនាទម្ងន់ជ្រូក៖

**ទទឹងជ្រូក (ម) × ទទឹងជ្រូក (ម) × បណ្តោយ (ម) × ៨៧.៥ = ទម្ងន់ជ្រូកស្រស់ប្រហាក់ប្រហែល (គ.ក្រ)**



**ទម្ងន់ជ្រូកស្រស់ អាចថ្លឹងបានដោយវាស់ ពីផ្នែកខាងលើនៃក្បាលជ្រូករហូតដល់កន្ទុយ និងបន្ទាប់មកវាស់ជុំវិញទទឹងជ្រូក តាមរយៈការប្រើប្រាស់រូបមន្តខាងក្រោម៖**

**ទទឹងជ្រូក (មប × ទទឹងជ្រូក (មប × បណ្តោយ (មប × ៨៧.៥ =**
**ទម្ងន់ជ្រូកស្រស់ប្រហាក់ប្រហែល (គ.ក្រប**

លទ្ធផលនៃការផ្តល់ចំណីតាមបែបប្រព័ន្ធដែលមានការលំអដល់កូនជ្រូកក្នុងរយៈពេលដំបូងនៃការចិញ្ចឹមមានដូចខាង ក្រោម៖

- កូនជ្រូកមានការធំធាត់លឿន គឺរហូតដល់ ៤០-៥០គ.ក្រ (អាស្រ័យទៅលើពូជ និងទម្ងន់ដំបូង) ក្នុងកំឡុងពេលប្រហែល ១០០ថ្ងៃ និង កូនជ្រូកអាចផលិតសាច់បានច្រើន។
- កូនជ្រូកមានកំលាំងខ្លាំង និងធន់នឹងជម្ងឺ។
- ជ្រូកអាចលក់បានយ៉ាងឆាប់ជាងជ្រូកដែលចិញ្ចឹមតាមបែបបុរាណ។
- ជ្រូកមានសមាសភាពសាច់ច្រើនជាងជ្រូក ដែលចិញ្ចឹមតាមបែបបុរាណ។






ជ្រូកដែលផ្តល់ចំណីលាយរវាងចំណីពាណិជ្ជកម្មដែលមានប្រូតេអ៊ីនខ្ពស់ កន្ទក់ និង ចុងអង្ករ មានការកើនទម្ងន់យ៉ាងលឿន រហូតដល់ ៤០-៥០ គ.ក្រ បន្ទាប់ពីរយៈពេលប្រហែល ១០០ ថ្ងៃ

**២.២.៤- នៅពេលដែលចំណីផ្សំខាងលើអស់ ត្រូវផ្តល់ចំណីតាមបែបបុរាណវិញ ប៉ុន្តែត្រូវផ្តល់ចំណីតាមបែបបុរាណនោះរួមផ្សំទៅ នឹងការផ្តល់ទឹកឱ្យបានគ្រប់គ្រាន់**

នៅពេលចំណីពាណិជ្ជកម្មចំនួន ៣០គ.ក្រ អស់ កសិករមានជម្រើសជាច្រើន រួមមាន:

- ប្រើប្រាស់ការលាយចំណីតាមបែបបុរាណរវាងកន្ទក់ ចុងអង្ករ និង ចំណីប្រូតេអ៊ីនក្នុងស្រុកដែលកសិករអាចរកបាន។ ឧទាហរណ៍ ផលិតផលត្រី រឺ ត្រកួន។
- បន្តនូវការផ្តល់ចំណីដែលបានកែលំអ។ ប្រសិនបើកសិករធ្វើរបៀបនេះ កសិករគួរអនុវត្តន៍តាមការណែនាំ ដូចបង្ហាញក្នុងតារាងខាងក្រោម:

តារាងទី៥. អត្រាលាយនៃចំណីពាណិជ្ជកម្មដែលមានប្រូតេអ៊ីនខ្ពស់ជាមួយចុងអង្ករ និង កន្ទក់

| **អត្រាលាយនៃចំណីពាណិជ្ជកម្មដែលមានប្រូតេអ៊ីនខ្ពស់ជាមួយចុងអង្ករ និង កន្ទក់** | | | |
|---|---|---|---|
| ទម្ងន់ជ្រូក | ចំណីពាណិជ្ជកម្ម ដែលមានប្រូតេអ៊ីន | ចុងអង្ករ | កន្ទក់ |
| ពីពេលផ្តាច់ដោះរហូតដល់ទម្ងន់ ២០ គ.ក្រ | ១ | ១ | 0,៥ |
| ទម្ងន់ ២០ គ.ក្រ ដល់ ៤០ គ.ក្រ | ១ | ១ | ១ |
| ទម្ងន់ ៤០ គ.ក្រ ដល់ ៦០ គ.ក្រ | ១ | ២ | ១ |
| ទម្ងន់ ៦០ គ.ក្រ រហូតដល់លក់ | ១ | ២ | ២ |

ចាប់ពី "បទដ្ឋានអនុវត្តបច្ចេកវិទ្យា" នេះត្រូវបានអនុវត្តន៍ទៅលើកសិករក្រីក្រដែលមានធនធានតិចតួច កសិករត្រូវបានគេរំពឹងថាពុំមានថវិកាគ្រប់គ្រាន់ក្នុងការទិញចំណីពាណិជ្ជកម្មឱ្យបានច្រើន។ អាស្រ័យហេតុនេះ កសិករអាចត្រូវការ ផ្លាស់ប្តូរទៅរកចំណីតាមបែបធម្មជាតិវិញសម្រាប់វគ្គចុងក្រោយនៃការផ្តល់ចំណីជ្រូក។

ដើម្បីប្រៀបធៀបការលូតលាស់ជ្រូក នៅក្រោមជម្រើសផ្សេងៗ ទាំងនេះ ក្រាហ្វិកខាងក្រោមបង្ហាញពីគំរូនៃការធំធាត់នៅក្រោមលក្ខខណ្ឌនេះ

DRAFT

• ប្រព័ន្ធគ្រប់គ្រងដោយមានការកែលំអកំរិតខ្ពស់គ្រប់រយៈពេលនៃការលូតលាស់របស់ជ្រូក ។
• ប្រព័ន្ធគ្រប់គ្រងដោយមានការកែលំអកំរិតខ្ពស់សម្រាប់កូនជ្រូក បន្ទាប់មកនៅក្រោមលក្ខ័ណ្ឌនៃប្រព័ន្ធគ្រប់គ្រងដោយមានការកែលំអកំរិតមធ្យមដែលមានចំណីតាមបែបបុរាណដែលមានគុណភាពខ្ពស់។ នៅក្នុងប្រព័ន្ធនេះ ជ្រូកមានទម្ងន់ ៩០គ.ក្រ បន្ទាប់ពីមានរយៈពេល ១៨០ថ្ងៃ។
• ប្រព័ន្ធគ្រប់គ្រងដោយមានការកែលំអកំរិតទាបគ្រប់រយៈពេលនៃការលូតលាស់របស់ជ្រូក។

ក្រាហ្វិកទី៣៰: ការធំធាត់របស់ជ្រូកនៅក្រោមប្រព័ន្ធគ្រប់គ្រងដោយមានការកែលំអកំរិតខ្ពស់ មធ្យម និង ទាប




## ២.២.៥- ស្នូកទឹកនិងចំណីត្រូវស្អាតជានិច្ច

កូនជ្រូកត្រូវការផឹកទឹកយ៉ាងច្រើន។ នៅពេលកូនជ្រូកទើបកើត រូបរាង្គកាយរបស់វាមានជាតិទឹកប្រហែល ៨០ភាគរយ។ ក្នុងខណៈដែលកូនជ្រូកមានការលូតលាស់ ភាគរយនៃទឹកនៅក្នុងរូបរាង្គកាយរបស់វាមានការថយចុះគឺ ជ្រូកទម្ងន់ ១០០គ.ក្រ មានជាតិទឹកប្រហែល ៦០ ភាគរយ (៦០ គ.ក្រ)។

កូនជ្រូកដែលចិញ្ចឹមតាមបែបបុរាណ គឺមិនត្រូវបានផ្តល់ទឹកដោយឡែកទេ។ ជាទូទៅ ទឹកត្រូវបានលាយជាមួយចំណីជាស៊ុប រួចផ្តល់ទៅឱ្យកូនជ្រូក ៣ដង ក្នុង១ថ្ងៃ។ នៅពេលកូនជ្រូកមានការរាគរូស ពួកគេបាត់បង់ជាតិទឹកយ៉ាងលឿន ប្រសិនបើមិនបានផឹកទឹកឱ្យបានគ្រប់គ្រាន់ ។

ការផ្តល់ទឹកដោយសេរីដល់កូនជ្រូក នឹងធ្វើឱ្យមានភាពប្រសើរឡើងនូវសុខភាព និងការលូតលាស់របស់វា។ ជាទូទៅ សម្រាប់ចំណី ១គ.ក្រ ដែលកូនជ្រូកស៊ី យើងគួរផ្តល់ទឹកចំនួន ៣ លីត្រ។

## ២.២.៦-ព្យាបាលកូនជ្រូកដោយ អ៊ីវ៉ឺម៉ិចទីន ក្នុងរយៈពេលដែលកូនជ្រូកស៊ីចំណី និង ផឹកទឹកបានច្រើន។ ព្យាបាលកូនជ្រូក ម្តងទៀត បន្ទាប់ពី១ខែក្រោយមក

កូនជ្រូកនៅប្រទេស កម្ពុជា ជាធម្មតាបានឆ្លងពី:

• ពពួកព្រូនធំៗមានរាងមូលដែលរស់នៅក្នុងពោះវៀនតូច ដែលបណ្តាលឱ្យជ្រូកទល់លាមក រាគរូស ថយចុះការស៊ីចំណី និង ការលូតលាស់ដែលមានអាយុ ២-៤ ខែ។

- ពពួកសត្វល្អិតដែលរស់នៅលើស្បែក ដែលបណ្តាលឱ្យជ្រូករមាស់ ថយចុះការស៊ីចំណី និងការលូតលាស់នៅពេលដែលកូនជ្រូកមានអាយុ ៥-៦ ខែ។

មានថ្នាំសំលាប់ប៉ារ៉ាស៊ីតច្រើនប្រភេទដែលអាចរកបានដូចជាៈ

- អ៊ីវឺម៉ិចទីន គឺសំលាប់ពពួកព្រូនមូល និង សត្វល្អិត
- លីវ៉ាមីហ្សុលគឺសំលាប់ពពួកព្រូនមូល និង មានប្រសិទ្ធិភាពខ្សោយជាងថ្នាំ អ៊ីវឺម៉ិចទីន

មានការណែនាំថា ទោះបីជាថ្នាំអ៊ីវឺម៉ិចទីនមានតម្លៃថ្លៃជាងថ្នាំលីវ៉ាមីហ្សុល ប៉ុន្តែវានៅតែមានតម្លៃថោក។ អ៊ីវឺម៉ិចទីនមានតម្លៃប្រហែល ២០០០ រៀលក្នុង ១ សេសេ សម្រាប់ព្យាបាលជ្រូកទម្ងន់ ៣០ គ.ក្រ។ អាស្រ័យហេតុនេះ តម្លៃថ្នាំសម្រាប់ជ្រូកទម្ងន់ ២០គ.ក្រ គឺ ៦៥០ រៀល។ ថ្លៃសេវ៉ាអាចដល់ ២០០០ រៀល។

អ៊ីវឺម៉ិចទីនអាចសំលាប់ពពួកព្រូនយ៉ាងលឿន ហើយកសិករអាចឃើញព្រូនស ងាប់នៅក្នុងលាមកជ្រូកក្នុងរយៈពេល ១ថ្ងៃបន្ទាប់ពីព្យាបាល ។

### ២.២.៧- ចាក់វ៉ាក់សាំងប៉េស្ត៍ និង សាទឹក ដល់កូនជ្រូក ក្នុងរយៈពេល ២-៣ថ្ងៃ បន្ទាប់ពីការព្យាបាលប៉ារ៉ាស៊ីត

ជម្ងឺប៉េស្ត៍ និងសាទឹក គឺជាជម្ងឺជ្រូកដែលតែងតែកើតនៅប្រទេសកម្ពុជា។ ក្នុងការចិញ្ចឹមជ្រូកតាមបែបបុរាណ ជ្រូកមិនត្រូវបានចាក់វ៉ាក់សាំង ហើយជ្រូកជាច្រើនងាប់ក្នុងរយៈពេលផ្ទុះជម្ងឺ។

កូនជ្រូកគួរចាក់វ៉ាក់សាំងប្រឆាំងនឹងជម្ងឺទាំងនេះ ក្នុងរយៈពេល ៣ថ្ងៃ បន្ទាប់ពីការព្យាបាលប៉ារ៉ាស៊ីតជាលើកដំបូង។

វ៉ាក់សាំងប៉េស្ត៍ដែលប្រើប្រាស់ច្រើនជាងគេ គឺផលិតពី ណាវិតកូ (ប្រទេស វៀតណាម) និងត្រូវបានផលិតក្នុងដបដែលមាន ១០កំរិតក្នុងទំរង់ស្ងួត។ វ៉ាក់សាំងនេះត្រូវបានលាយជាមួយទឹកស្អាតចំនួន ២០ មីលីលីត្រ ដើម្បីបង្កើតឱ្យបាន ១០កំរិត នៃចំណុះ ២មីលីលីត្រក្នុងមួយៗ។ តម្លៃលក់រាយ គឺប្រហែល ៤០០រៀលក្នុង១កំរិត រឺ ៤០០០រៀលក្នុង១ដប។ តម្លៃទីផ្សារសម្រាប់ការចាក់វ៉ាក់សាំង ក្នុង ១ក្បាល គឺ ប្រហែល ១០០០រៀល ។

វ៉ាក់សាំងសាទឹកដែលប្រើប្រាស់ច្រើនជាងគេ គឺផលិតពី ណាវិតកូ (ប្រទេស វៀតណាម)។

### ២.២.៨- ហៅភ្នាក់ងារពេទ្យសត្វភូមិនៅពេលដែលកូនជ្រូកឈឺ

កូនជ្រូកអាចឈឺដោយការកើតជម្ងឺផ្សេងៗ ។ រោគសញ្ញាជារួម គឺ រាគ និង ទល់លាមក រឺ ក្អក រឺ ឈប់ស៊ីចំណីអាហារ។ កសិករក្រីក្រដែល ចិញ្ចឹមជ្រូកតាមបែបបុរាណៈ

ជាញឹកញាប់ទិញថ្នាំពីឱសថដ្ឋានក្នុងភូមិដែលមានទំរង់ជាគ្រាប់ រួចដាក់ចូលក្នុងចំណី។ ថ្នាំនេះពុំមានប្រសិទ្ធិភាពសម្រាប់ ជ្រូកដែលឈឺ។

- ជាញឹកញាប់លក់ជ្រូកនៅពេលដែលជ្រូកឈឺ ពីព្រោះពួកគេព្រួយបារម្ភថាជ្រូកនឹងងាប់។ បញ្ហានេះកើតឡើងជាញឹកញាប់បន្ទាប់ពីការបរាជ័យក្នុងការព្យាបាល។

ការអញ្ជើញភ្នាក់ងារពេទ្យសត្វភូមិដែលត្រូវបានបណ្តុះបណ្តាលរួចហើយ គឺមានប្រយោជន៍ណាស់ព្រោះពួកគេព្យាបាល សត្វឈឺដោយប្រើថ្នាំត្រូវទៅនឹងប្រភេទនៃជម្ងឺ។

### ២.២.៩- ធ្វើការលក់ដូរកូនជ្រូកឱ្យមានប្រសិទ្ធិភាព

ប្រព័ន្ធលក់ដូរនៃការចិញ្ចឹមជ្រូកបំប៉នមួយក្បាលតាមបែបបុរាណ គឺបានបង្ហាញនូវលក្ខណៈដូចខាងក្រោមៈ

- ធ្វើការលក់ដូរជ្រូកនៅទីកន្លែងចិញ្ចឹម ទៅអោយឈ្មួញដែលធ្វើដំណើរក្នុងភូមិដោយមានដាក់កន្ត្រកនៅពីក្រោយម៉ូតូ

DRAFT

- កសិករត្រូវការកំណត់អាយុនិងទម្ងន់ជ្រូកនៅពេលលក់។ នៅពេលដែលកសិករត្រូវការលុយ រឺ ខ្វះលុយក្នុងការទិញចំណី រឺ បារម្ភពីជ្រូកឈឺ កសិករនឹងលក់ជ្រូកចេញ។ កសិករដែលក្រីក្រជាធម្មតាលក់ជ្រូកក្នុងទម្ងន់ ៦០-៧០គ.ក្រ។ ទោះបីជាយ៉ាងណាក៏ដោយ កសិករនៅតែទទួលប្រាក់ចំណេញរហូតដល់ជ្រូកមានទម្ងន់ ៩០គ.ក្រ សូម្បីគិតតាំងពី ចំណាយលើចំណីជាប្រចាំថ្ងៃ ការប្រាក់លើថ្លៃដើមរបស់ជ្រូក និង ការកើនទម្ងន់របស់ជ្រូក។
- ជ្រូកត្រូវបានថ្លឹងដោយប្រើប្រាស់ជញ្ជីងរបស់ឈ្មួញ ហើយតម្លៃក្នុង១គ.ក្រនៃទម្ងន់ស្រស់ត្រូវបានចរចារវាងឈ្មួញ និង កសិករ ដោយឈ្មួញកំណត់តម្លៃដោយផ្អែកទៅលើទម្ងន់សាច់ សមាសភាពសាច់និងខ្លាញ់ ការវាយតម្លៃ ដោយផ្អែកនូវ អាយុ ពូជ និងប្រភពនៃការផ្តល់ចំណីរបស់ជ្រូក។



**ជ្រូកដែលចិញ្ចឹមតាមបែបបុរាណមានខ្លាញ់ច្រើននៅពេលពិឃាដ ។ ជ្រូកដែលចិញ្ចឹមដោយផ្តល់ចំណីដែលមានប្រូតេអ៊ីន ខ្ពស់មានខ្លាញ់តិច ។ ហេតុដូច្នេះហើយតម្លៃរបស់វាជាប្រាក់រៀលខ្ពស់ជាងក្នុង១ គ.ក្រ នៅពេលលក់ ។**

DRAFT

ជ្រូកភាគច្រើនដែលចិញ្ចឹមតាមបែបបុរាណមានខ្លាញ់ច្រើន និង សាច់តិច ដែលជាហេតុធ្វើឱ្យឈ្មួញបន្ទាបតម្លៃ។ ការណែនាំលើការលក់ដូរអាចជាបញ្ហាទូទៅមួយ ។ ទោះបីជាយ៉ាងណាក៏ដោយ កសិករគួរ:

- គណនាទម្ងន់ជ្រូករបស់គាត់ ដោយប្រើប្រាស់ខ្សែសម្រាប់វាស់រៀងរាល់អាទិត្យ ហើយធ្វើរបៀបនេះដើម្បីផ្តល់ជាព័ត៌មានក្នុងការពិនិត្យថាតើពេលណាដែលជាពេលល្អដែលគួរលក់ជ្រូក។ ក្នុងស្ថានភាពជាច្រើន កសិករនឹងបន្តទទួល ប្រាក់ចំណេញរហូតដល់ជ្រូកមានទម្ងន់ ៩០គ.ក្រ។ កសិករគួរពិនិត្យជញ្ជីងថ្លឹងរបស់ឈ្មួញ។
- ផ្តល់ព័ត៌មានដល់ឈ្មួញថា ជ្រូកត្រូវបានផ្តល់ចំណីដែលមានគុណភាពល្អ ហើយដូច្នេះជ្រូកនឹងមានសាច់ច្រើន និងមានតម្លៃ ខ្ពស់។

## ២.៣ ផលចំណេញផ្នែកសេដ្ឋកិច្ច

វាមានទំនាក់ទំនងផ្សេងៗគ្នាដែលអាចកើតឡើងនៅពេលចិញ្ចឹមជ្រូកមួយក្បាលរួមមាន:

- កូនជ្រូកអាចផ្តល់ចំណីគ្រប់ប្រភេទ
- កូនជ្រូកអាចរឺមិនអាចចាក់វ៉ាក់សាំង

- កូនជ្រូកអាចរីមិនអាចឈឺ ដែលក្នុងនោះ ករណីដែលកូនជ្រូកអាចរីមិនអាចត្រូវបានព្យាបាល និងអាចរីមិនអាច រស់បាន។
- ជ្រូកអាចលក់បានក្នុងទម្ងន់ផ្សេងៗគ្នា គឺ ៦០-៩០គ.ក្រ

ការវិភាគសេដ្ឋកិច្ចដែលបានបង្ហាញក្នុងតារាងខាងក្រោម គឺសម្រាប់ប្រៀបធៀបប្រព័ន្ធការចិញ្ចឹមតាមបែបកែលំអកំរិតទាប និង ប្រព័ន្ធការចិញ្ចឹមតាមបែបកែលំអកំរិតមធ្យម។ នៅក្នុងប្រព័ន្ធទាំងពីរនេះ កូនជ្រូកទម្ងន់ ៧គ.ក្រ ដែលទិញក្នុងតម្លៃ៩០០០រៀល ក្នុង ១គ.ក្រ ត្រូវបានចងនៅក្រោមផ្ទះ។ កូនជ្រូកត្រូវបានព្យាបាលអស់តម្លៃ ១០០០០រៀល ហើយលក់ក្នុងទម្ងន់ ៧០គ.ក្រ។ ប្រព័ន្ធទាំងពីរនេះត្រូវ បានជ្រើសរើស ដើម្បីផ្តោតទៅលើប្រសិទ្ធិភាពនៃការផ្តល់ចំណីដែលមានគុណភាពខ្ពស់ ជាជាងប្រសិទ្ធិភាពនៃសុខភាពសត្វដែលបាន កែលំអ។

នៅក្នុងប្រព័ន្ធការចិញ្ចឹមតាមបែបកែលំអកំរិតទាប

- ជ្រូកត្រូវបានផ្តល់ចំណីដែលមានល្បាយចុងអង្ករ និងកន្ទក់ក្នុងទំរង់ជាស៊ុប កាកសំណល់ផ្ទះបាយ និងត្រកួន ហើយជ្រូក មានការរីកលូតលាស់ជាមធ្យម ២៥២ក្រ ក្នុង១ថ្ងៃ ក្នុងកំឡុងពេល ២៥០ថ្ងៃ។
- ជ្រូកដែលលក់មានខ្លាញ់ខ្ពស់ និងមានតម្លៃ ៤៥០០រៀលក្នុង ១គ.ក្រ នៃទម្ងន់ស្រស់។

នៅក្នុងប្រព័ន្ធការចិញ្ចឹមតាមបែបកែលំអកំរិតមធ្យមៈ

- កសិករអនុវត្តន៍តាមការណែនាំនៃ “ បទដ្ឋានអនុវត្តបច្ចេកវិទ្យា ” ដោយគោរពទៅតាម ការផ្តល់ចំណី និងសុខភាព។
- កូនជ្រូកមានការរីកលូតលាស់ ៤២០ក្រ.ក្នុង ១ថ្ងៃ និងត្រូវបានលក់ក្នុងទម្ងន់ ៧០គ.ក្រ បន្ទាប់ពីរយៈពេល ១៥០ថ្ងៃ ក្នុង តម្លៃ ៤៨០០រៀលក្នុង ១គ.ក្រ។

តារាងទី៦. ការប្រៀបធៀបសេដ្ឋកិច្ចនៃប្រព័ន្ធការចិញ្ចឹមជ្រូកបំប៉នតាមបែបបុរាណនិងការកែលំអ

| **ការប្រៀបធៀបសេដ្ឋកិច្ចនៃប្រព័ន្ធការចិញ្ចឹមជ្រូកបំប៉នតាមការកែលំអកំរិតទាប និង មធ្យម** | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ការកែលំអកំរិតទាប | | | | ការកែលំអកំរិតមធ្យម | | | |
| | ឯកតា | តម្លៃរៀល/ ឯកតា | ចំនួន ឯកតា | តម្លៃ រៀល | ឯកតា | តម្លៃរៀល/ ឯកតា | ចំនួន ឯកតា | តម្លៃរៀល |
| **ចំណាយអាចប្រែប្រួល** | | | | | | | | |
| កូនជ្រូក | គ.ក្រ | ៩០០០ | ៤ | ៦៣០០០ | គ.ក្រ | ៩០០០ | ៧ | ៦៣០០០ |
| ចុងអង្ករ | គ.ក្រ | ៦០០ | ២០៩ | ១២៥៤០០ | គ.ក្រ | ៦០០ | ៩៥ | ៥៧០០០ |
| កន្ទក់ | គ.ក្រ | ៨០០ | ៥២ | ៤១៦០០ | គ.ក្រ | ៨០០ | ៥២ | ៤១៦០០ |
| ចំណីពាណិជ្ជកម្ម | គ.ក្រ | ២៤០០ | ០ | ០ | គ.ក្រ | ២៤០០ | ៣០ | ៧២០០០ |
| អ៊ីប៉ូមូអា | ថ្ងៃ | ១០០ | ២៣០ | ២៣០០០ | ថ្ងៃ | ១០០ | ៦០ | ៦០០០ |
| អ៊ីវ៉ូម៉ិច | សេសេ | ៤០០០ | ០ | ០ | សេសេ | ៤០០០ | ០.៣ | ១២០០ |
| វ៉ាក់សាំងសាទឹក | ក្បាល | ១០០០ | ០ | ០ | ក្បាល | ១០០០ | ១ | ១០០០ |
| វ៉ាក់សាំងប៉េស្ត | ក្បាល | ១០០០ | ០ | ០ | ក្បាល | ១០០០ | ១ | ១០០០ |
| វ៉ាក់សាំងជម្ងឺរាគជ្រូក | ក្បាល | ១០០០ | ០ | ០ | ក្បាល | ១០០០ | ១ | ១០០០ |
| ថ្នាំប៉ារ៉ាស៊ីត | ក្បាល | ១០០០០ | ១ | ១០០០ | ក្បាល | ១០០០០ | ១ | ១០០០០ |
| | | | | **២៦៣ ០០០** | | | | **២៥៣ ៨០០** |

DRAFT

| **ប្រាក់ចំណូល** | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ការលក់ជ្រូក | គ.ក្រ | ៤៥០០ | ៧០ | ៣១៥.០០០ | គ.ក្រ | ៤៨០០ | ៧០ | ៣៣៦.០០០ |
| **ផលចំណេញ ក = ប្រាក់ចំណូល - ចំណាយអាចប្រែប្រួល** | | | | **៥២០០០** | | | | **៨២២០០** |
| **តម្លៃមិនប្រែប្រួល** | | | | | | | | |
| តម្លៃស្ទូក | ឯកតា | ២០០០០ | ០ | ០ | ឯកតា | ២០០០០ | ២ | ៤០០០០ |
| **ផលចំណេញ ខ = ផលចំណេញ ក - ចំណាយមិនប្រែប្រួល** | | | | **៥២០០០** | | | | **៤២២០០** |
| **ផលចំណេញ ក ក្នុង១ថ្ងៃ** | រៀល ក្នុង ១ថ្ងៃ | | | ២០៨ | រៀល ក្នុង ១ថ្ងៃ | | | ៥៤៨ |

| **ការវិភាគបច្ចេកទេសនៃប្រព័ន្ធការចិញ្ចឹមជ្រូកបំប៉នតាមការកែលំអកំរិតទាប និង មធ្យម** | | | |
|---|---|---|---|
| | | ការកែលំអកំរិតទាប | ការកែលំអកំរិតមធ្យម |
| ចំនួនជ្រូក | ក្បាល | ១ | ១ |
| ទម្ងន់ចាប់ផ្តើម | គ.ក្រ | ៧ | ៧ |
| រយះពេលលូតលាស់ | ថ្ងៃ | ២៥០ | ១៥០ |
| ទម្ងន់លក់ | គ.ក្រ | ៧០ | ៧០ |
| អត្រាលូតលាស់ជាមធ្យម | គ.ក្រ/ថ្ងៃ | ០,២៥២ | ០,៤២០ |
| ពលកម្ម | ថ្ងៃ | ២១ | ១៣ |
| ការផ្លាស់ចំណី | | ៤.៩ | ៣,០ |
| វដ្តក្នុងរយៈពេល ៣ឆ្នាំ | | ៤ | ៧ |

## ៣. ការណែនាំលើការងារផ្សព្វផ្សាយ

គោលការណ៍ផ្សព្វផ្សាយ គឺផ្តោតទៅលើកម្មវិធីផ្សព្វផ្សាយថ្នាក់ឃុំ។ គោលការណ៍ទាំងនេះ អាចតម្រូវទៅនឹងតំបន់អនុវត្តទំហំតូចតាច (ឧទាហរណ៍: ភូមិ) រឺ ធំ (ឧទាហរណ៍: ស្រុក ខេត្ត)។ ចំនួនទីកន្លែងនៃការធ្វើបង្ហាញនៅក្នុងភូមិនីមួយៗ និងចំនួនភូមិ នឹងអាស្រ័យទៅលើប្រភពធនធាន។

### ៣.១. ការរៀបចំស្ថាប័ន

អ្នកចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយនេះមាន:

ក- មន្ត្រីការិយាល័យផលិតកម្មនិងបសុព្យាបាលនិងមន្ត្រីផ្សព្វផ្សាយតាមខេត្ត។ សមាជិកនៃមន្ត្រីថ្នាក់នេះ គឺទទួលខុសត្រូវក្នុងការងារសំរបសំរួល ទូទៅនៃការផ្សព្វផ្សាយ។

ខ- មន្ត្រីពេទ្យសត្វនៃការិយាល័យកសិកម្មស្រុក ដែលនៅក្រោមកិច្ចសន្យាក្នុងការគ្រប់គ្រងសកម្មភាពរបស់កម្មវិធីក្នុងស្រុក។ ប្រធានការិយាល័យកសិកម្មថ្នាក់ស្រុក នឹងមានតួនាទីគាំទ្រកម្មវិធីផងដែរ។

DRAFT

គ- ពេទ្យសត្វភូមិមានកិច្ចសន្យាក្នុងការផ្តល់សេវាសុខភាពសត្វ នឹងជួយធ្វើផែនការប្រជុំ និងវាយតម្លៃ។ ប្រសិនបើពេទ្យ* សត្វភូមិត្រូវបានរៀបចំជាសមាគម នោះការរៀបចំផ្ទៃក្នុងមួយរបស់សមាគមពេទ្យសត្វភូមិនឹងត្រូវបាន គិតគូរពិចារណា គឺថាប្រធានសមាគមមានតួនាទីសំខាន់ ហើយសមាគមអាចត្រូវបានធ្វើកិច្ចសន្យា។ ក្នុងផ្នែកនៃកិច្ចសន្យា ពេទ្យសត្វភូមិ ទទួលអ៊ីវ៊ែរម៉ិច១ដប និង វ៉ាក់សាំងប៉េស្តិ៍ ១ដប និង សាទីក១ដប។

ឃ- អាជ្ញាធរដែនដីត្រូវតែជួយក្នុងការជ្រើសរើសកសិករ និង ចូលរួមកិច្ចប្រជុំក្នុងការធ្វើផែនការថ្នាក់ឃុំ។

ង- អ្នកលក់ចំណីពាណិជ្ជកម្មតូចតាច ។ អ្នកទាំងនេះទទួលការហ្វឹកហ្វឺនលើបច្ចេកទេស និង ហិរញ្ញវត្ថុនៃការចិញ្ចឹមជ្រូក និង ការប្រើប្រាស់ចំណី។

ច- កសិករគំរូ (គ្រួសារក្នុងមួយភូមិ) ដែលឋិតនៅក្រោមកិច្ចសន្យាជាមួយថ្នាក់ស្រុកក្នុងការគ្រប់គ្រងជ្រូក នៅទីកន្លែងធ្វើ បង្ហាញ។ កសិករគំរូទទួលចំណីដែលមានប្រូតេអ៊ីន ៤០ភាគរយ មួយបាវទម្ងន់ ៣០គ.ក្រ ស្នូកពីរសម្រាប់ដាក់ទឹក និងចំណី ម៉ែត្រសម្រាប់វាស់ ថ្នាំសម្រាប់ព្យាបាលប៉ារ៉ាស៊ីត (អ៊ីវ៉ឺម៉ិច) និងវ៉ាក់សាំងប៉េស្តិ៍ដោយមិនបាច់បង់លុយ និងជញ្ជីងទម្ងន់ ១០ គ.ក្រ ក្នុងរយៈពេលធ្វើបង្ហាញ។ កសិករគំរូនឹងផ្តល់កូនជ្រូកដែលទើបនឹងទិញ កន្ទក់ និងចុងអង្ករ សម្រាប់លាយជាមួយ ចំណីប្រូតេអ៊ីនផ្សំ និងទទួលពលកម្មក្នុងការគ្រប់គ្រងជ្រូក និងរក្សាទុកទិន្នន័យ។ កសិករគំរូគួរមានសមត្ថភាពខ្ពស់នឹងមាន ជំនាញក្នុងការទំនាក់ទំនងជាអ្នកអាចទុកចិត្ត អាចផ្សព្វផ្សាយដល់កសិករផ្សេងទៀតបាន និងជាអ្នកដែលអាចរក្សាទុក ទិន្នន័យបានល្អ។

ឆ- កសិករចូលរួម (១៩នាក់ ក្នុងទីកន្លែងធ្វើបង្ហាញ) ដែលអាចចូលរួមក្នុងការធ្វើបង្ហាញជាក់ស្តែង។ កសិករទាំងនេះទទួល ការព្យាបាលនូវថ្នាំអ៊ីវ៉ឺម៉ិច ប៉េស្តិ៍ និងសាទីកដោយគ្រាន់តែបង់លុយលើថ្លៃសេវា។ កសិករដែលចូលរួម ទទួលបាននូវ កូនសៀវភៅ ប៊ិច និងម៉ែត្រសម្រាប់វាស់។ កសិករទាំងនេះកត់នូវទិន្នន័យនៃទម្ងន់ជ្រូកបំប៉នរបស់ខ្លួន និងធ្វើការប្រៀប ធៀបជ្រូករបស់ពួកគេទៅនឹងជ្រូករបស់កសិករគំរូ។ កសិករទាំងនេះគួរកំពុងចិញ្ចឹមជ្រូក ១-២ក្បាល តាមបែបបុរាណ និងមានចំណង់ចំណូលចិត្តក្នុងការធ្វើឱ្យជ្រូករបស់ពួកគេ មានភាពល្អប្រសើរឡើង។

ជ- កសិករដទៃទៀតដែលអាចមានសិទ្ធិចូលក្នុងទីកន្លែងធ្វើបង្ហាញ និងគួរទទួលព័ត៌មានពីកសិករគំរូ និងកសិករដែលចូលរួម។

អាស្រ័យទៅនឹងប្រភពធនធាន និងទំហំនៃភូមិ ចំនួនកសិករក្នុងក្រុម រឺចំនួនក្រុមក្នុងភូមិអាចត្រូវបានកើនឡើង។

## ៣.២. ការធ្វើផែនការសកម្មភាព

ផែនការសកម្មភាពមានរយៈពេលប្រហែល ៦ខែ ដែលរួមមានការធ្វើផែនការ ការអនុវត្តនូវការធ្វើបង្ហាញ និង វគ្គពិនិត្យ និង វាយតម្លៃ ។

DRAFT

ក្រាហ្វិកទី ៤. ផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងជ្រូកបំប៉នមួយក្បាល

| **ផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងជ្រូកបំប៉នមួយក្បាល** | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សកម្មភាព | ខែ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ការជ្រើសរើសទីកន្លែង | | | | | | | | | | | | |
| ការប្រជុំថ្នាក់ឃុំលើកទី ១ និង ២ | | | | | | | | | | | | |
| ការហ្វឹកហ្វឺនអ្នកលក់ចំណី លើកទី ១ និង ២ | | | | | | | | | | | | |
| ការជ្រើសរើសកសិករ | | | | | | | | | | | | |
| ការទស្សនៈកិច្ច៤ថ្ងៃ នៅទីកន្លែងធ្វើបង្ហាញ | | | | | | | | | | | | |
| ការត្រួតពិនិត្យរបស់ភ្នាក់ងារពេទ្យសត្វភូមិ | | | | | | | | | | | | |
| ការត្រួតពិនិត្យអ្នកគ្រប់គ្រងថ្នាក់ស្រុក | | | | | | | | | | | | |
| ការត្រួតពិនិត្យអ្នកសំរបសំរួលថ្នាក់ខេត្ត | | | | | | | | | | | | |

## ការជ្រើសរើសទីកន្លែង

គ្រប់ភូមិក្នុងស្រុកដែលឆ្លើយតបតាមលក្ខខណ្ឌសមស្របទៅនឹងបច្ចេកទេស គឺត្រូវបានជ្រើសរើសជាទីកន្លែងអនុវត្តកម្មវិធី ។ ចំនួនទីកន្លែងនៃការធ្វើបង្ហាញក្នុង១ភូមិ និងចំនួនភូមិក្នុង១ឃុំ គឺអាស្រ័យទៅនឹងប្រភពធនធាន ។

## ការប្រជុំថ្នាក់ស្រុកលើកទី ១

នៅក្នុងការប្រជុំដែលត្រូវបានចូលរួមដោយមន្ត្រីថ្នាក់ស្រុក អាជ្ញាធរមូលដ្ឋាន និង ភ្នាក់ងារពេទ្យសត្វភូមិក្នុងឃុំ មន្ត្រីថ្នាក់ស្រុកៈ

- ពន្យល់ទិសដៅនៃកម្មវិធី សកម្មភាព គោលដៅ រចនាសម្ព័ន្ធ ផែនការសកម្មភាព និង កិច្ចសន្យារបស់ ពេទ្យសត្វភូមិ ។
- ផ្តល់នូវបច្ចេកវិទ្យាសំខាន់ៗនៃការលូតលាស់ ចំណី សុខភាពរបស់ជ្រូក និងការវិភាគសេដ្ឋកិច្ចដែលនៅក្នុងនោះ មានការ ប្រៀបធៀបនូវប្រព័ន្ធការចិញ្ចឹមតាមបែបកែលំអកំរិតទាប មធ្យម និង ខ្ពស់ ។
- អត្ថាធិប្បាយ និង ចុះកិច្ចសន្យាជាមួយពេទ្យសត្វភូមិ ។

- ពន្យល់កិច្ចសន្យារបស់កសិករគំរូ និង លក្ខខណ្ឌក្នុងការជ្រើសរើសកសិករ ។

## ការហ្វឹកហ្វឺនអ្នកលក់ចំណីលើកទី ១

អ្នកលក់ថ្នាំនិងចំណីទទួលការហ្វឹកហ្វឺនលើ:

- បច្ចេកវិទ្យានៃចំណី សុខភាព និង សេដ្ឋកិច្ចនៃការគ្រប់គ្រងជ្រូកបំប៉ន។
- ប្រព័ន្ធពេទ្យសត្វភូមិ និង ប្រភេទថ្នាំជាមូលដ្ឋាន និង របៀបឆ្លើយតបទៅនឹងសំនួររបស់កសិករ។
- ការប្រើប្រាស់និងប្រសិទ្ធិភាពនៃចំណីពាណិជ្ជកម្មសម្រាប់ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ។

ការហ្វឹកហ្វឺន គឺផ្តោតទៅលើរបៀបកែលំអនូវជំនួញរបស់ពួកគេ និងត្រូវបានបង្រៀនដោយអ្នកគ្រប់គ្រងថ្នាក់ខេត្ត ដោយមានជំនួយពីអ្នកគ្រប់គ្រងថ្នាក់ស្រុក រឺ ភ្នាក់ងារពេទសត្វភូមិ ដែលអ្នកទាំងនោះជាប្រភពធនធាន។

## ការជ្រើសរើសកសិករ

មន្ត្រីស្រុក ភ្នាក់ងារពេទ្យសត្វភូមិ និងអាជ្ញាធរដែនដី បានសហការគ្នាក្នុងការជ្រើសរើសកសិករគំរូ ពិនិត្យកន្លែងបង្ហាញ និង ជ្រើសរើសកសិករដែលចូលរួម។ កិច្ចសន្យារបស់កសិករគំរូត្រូវបានពិភាក្សា និងសំរេច។ មន្ត្រីស្រុកបង្ហាញកសិករពីរបៀបទុកដាក់ទិន្នន័យ និងប្រគល់នូវអ្វីដែលទទួលបានជូនកសិករគំរូ។

## ការទស្សនៈកិច្ចថ្ងៃទី១

ការទស្សនៈកិច្ចថ្ងៃទី១ គួរធ្វើឡើងបន្ទាប់ពីកូនជ្រូកត្រូវបានទិញនៅកន្លែងកសិករគំរូ។ នៅថ្ងៃទី១នៃការធ្វើទស្សនៈកិច្ចនេះ ៖

- មន្ត្រីស្រុកពន្យល់សកម្មភាពនៅទីកន្លែងនៃការធ្វើបង្ហាញ។
- ត្រូវបង្ហាញពីការព្យាបាលប៉ារ៉ាស៊ីត ការចាក់វ៉ាក់សាំង ស្នូកទឹកនិងចំណី ការលាយនិងផ្តល់ចំណី ការវាស់ទម្ងន់ ដោយខ្សែ។
- ការពិភាក្សាជាក្រុមលើការលូតលាស់ និងការលក់ដូរជ្រូក។

## ការទស្សនៈកិច្ចថ្ងៃទី២

ការងារនេះគួរធ្វើឡើងប្រហែល១ខែក្រោយមកនៅកន្លែងកសិករគំរូ ។ ក្រុមៈ

- ពិនិត្យជ្រូកនៅកន្លែងកសិករគំរូ។
- ពិនិត្យការកត់ត្រារបស់កសិករគំរូ។
- ពិភាក្សាការរីកចំរើននៃការចិញ្ចឹមជ្រូកគំរូ ហើយប្រៀបធៀបការចិញ្ចឹមជ្រូករបស់ពួកគេ ជាមួយការចិញ្ចឹមជ្រូករបស់កសិករដទៃទៀត។

## ការទស្សនៈកិច្ចថ្ងៃទី៣

ការងារនេះគួរធ្វើឡើងនៅពេលដែលចំណីពាណិជ្ជកម្មជិតអស់ (ប្រហែល៣ខែបន្ទាប់ពីការចិញ្ចឹម) នៅកន្លែងកសិករគំរូ។ ក្រុមៈ

- ពិនិត្យជ្រូកនៅកន្លែងកសិករគំរូ។
- ពិនិត្យការកត់ត្រារបស់កសិករគំរូ។
- ពិភាក្សាការរីកចំរើននៃការចិញ្ចឹមជ្រូកគំរូ ហើយប្រៀបធៀបការចិញ្ចឹមជ្រូករបស់ពួកគេ ជាមួយការចិញ្ចឹមជ្រូករបស់ កសិករដទៃទៀត។

DRAFT

## ការទស្សនៈកិច្ចថ្ងៃទី៤

ការងារនេះគួរធ្វើឡើងនៅពេលជ្រូកមានទម្ងន់ ៧០ គ.ក្រ បន្ទាប់ពីការចិញ្ចឹមមានរយៈពេល៥ខែ។ នៅថ្ងៃទី៥នេះ អ្នកចូលរួមៈ

- ពិនិត្យជ្រូកនៅកន្លែងកសិករគំរូ ។
- ពិនិត្យការកត់ត្រារបស់កសិករគំរូ ។
- ពិភាក្សាការរីកចំរើននៃការចិញ្ចឹមជ្រូកគំរូ ហើយប្រៀបធៀបការចិញ្ចឹមជ្រូករបស់ពួកគេ ជាមួយការចិញ្ចឹមជ្រូករបស់កសិករដទៃទៀត ក្នុងផ្នែកបច្ចេកវិទ្យា និង ហិរញ្ញវត្ថុ។
- ពិភាក្សាជម្រើសក្នុងការលក់ដូរជ្រូក ។

## ការត្រួតពិនិត្យភ្នាក់ងារពេទ្យសត្វភូមិ

ក្នុងចន្លោះពេលក្នុងការធ្វើទស្សនៈកិច្ចនេះ ភ្នាក់ងារពេទ្យសត្វភូមិ បន្តចុះត្រួតពិនិត្យសកម្មភាពកសិករគំរូ និងត្រួតពិនិត្យលើសកម្មភាព និងប្រតិកម្មនៃកសិករដែលចូលរួម ។

## ការត្រួតពិនិត្យអ្នកគ្រប់គ្រងថ្នាក់ស្រុក

អ្នកគ្រប់គ្រងថ្នាក់ស្រុកអាចធ្វើការចុះពិនិត្យ កសិករគំរូ និងភ្នាក់ងារពេទ្យសត្វភូមិជាប្រចាំ រឺ យូរ១ម្តង និងត្រួតពិនិត្យលើការអនុវត្តន៍ផ្នែកលើកិច្ចសន្យា និង ប្រតិកម្មរបស់កសិករ ។

## ការត្រួតពិនិត្យអ្នកសំរបសំរួលថ្នាក់ខេត្ត

អ្នកសំរបសំរួលថ្នាក់ខេត្ត ចុះធ្វើពិនិត្យម្តងម្កាលលើការអនុវត្តនៃកិច្ចសន្យារបស់អ្នកគ្រប់គ្រងស្រុកកសិករគំរូ និង ភ្នាក់ងារពេទ្យសត្វភូមិ និងធ្វើការវាយតម្លៃប្រតិកម្មតបវិញ និងការទទួលយកនូវបច្ចេកវិទ្យារបស់កសិករ ។

## ការប្រជុំថ្នាក់ឃុំលើកទី ២

នៅក្នុងកិច្ចប្រជុំដែលមានការចូលរួមដោយមន្ត្រីស្រុក ភ្នាក់ងារពេទ្យសត្វភូមិ និង អាជ្ញាធរដែនដី មន្ត្រីស្រុកដឹកនាំ ធ្វើការពិភាក្សាសន្និដ្ឋាន និងការណែនាំលើៈ

- ទិសដៅ សកម្មភាព គោលដៅ រចនាសម្ព័ន្ធ និង កិច្ចសន្យារបស់កម្មវិធី ។
- លទ្ធផលនៃទីកន្លែងធ្វើបង្ហាញក្នុងផ្នែកបច្ចេកវិទ្យា និងហិរញ្ញវត្ថុ និងធ្វើការប្រៀបធៀបវាទៅ និងការអនុវត្តតាមបែបបុរាណ ។
- ការអនុវត្តនៃកិច្ចសន្យារបស់កសិករគំរូ និង ភ្នាក់ងារពេទ្យសត្វភូមិ ។
- ចំណុចខ្លាំង ខ្សោយនៃបច្ចេកវិទ្យា ដំណើរការផ្សព្វផ្សាយ និងការរៀបចំស្ថាប័ន។
- ឱកាសដើម្បីកែលំអបច្ចេកវិទ្យា និង ដំណើរការផ្សព្វផ្សាយ ។

## ការហ្វឹកហ្វឺនអ្នកលក់ចំណីលើកទី ១

អ្នកលក់ថ្នាំ និងចំណី ទទួលការហ្វឹកហ្វឺនលើៈ

- លទ្ធផលនៃការធ្វើបង្ហាញ និងសក្តានុពលសម្រាប់ការបង្កើនប្រាក់ចំណូលតាមរយៈការលក់ចំណីជ្រូក ។

DRAFT

ការហ្វឹកហ្វឺន គឺផ្ដោតទៅលើពីរបៀបកែលំអនូវជំនួញរបស់ពួកគេ និងត្រូវបានបង្រៀនដោយអ្នកគ្រប់គ្រងថ្នាក់ខេត្ត ដោយមានជំនួយពីអ្នកគ្រប់គ្រងថ្នាក់ស្រុក រឺ ភ្នាក់ងារពេទ្យសត្វភូមិដែលបានជ្រើសរើស ហើយដែលអ្នកទាំងនោះជាប្រភពធនធាន។

## ៣.៣ ឧបករណ៍ និង សំភារៈ

បញ្ជីឧបករណ៍និងសំភារៈដែលត្រូវការសម្រាប់អនុវត្ត ៉បទដ្ឋានអនុវត្តបច្ចេកវិទ្យា ៉ បានបង្ហាញក្នុងតារាងខាងក្រោមៈ

តារាងទី៧. ឧបករណ៍ និង សំភារៈ

| |
|---|
| សៀវភៅសម្រាប់សរសេររបាយការណ៍របស់អ្នកគ្រប់គ្រងស្រុក |
| សៀវភៅសម្រាប់សរសេររបាយការណ៍របស់កសិករគំរូ |
| សៀវភៅសម្រាប់សរសេររបាយការណ៍របស់ភ្នាក់ងារពេទ្យសត្វភូមិ |
| ខិត្តប័ណ្ណស្ដីពីចំណេះដឹងនៃការផ្ដល់ចំណីជ្រូក |

## ៣.៤ ថវិកាសម្រាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតម្រូវការជាក់ស្ដែងនៃសាមុីអង្គភាព។ តារាងថវិកា ខាងក្រោមបានបង្កើត ឡើងក្នុងឆ្នាំ២០០៦ ដោយយោងទៅលើការប៉ាន់ស្មានលើបទដ្ឋានអនុវត្តបច្ចេកវិទ្យា របស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

តារាងទី៨. ថវិកាសម្រាប់អនុវត្តន៍គំរោង

| **ថវិកា និងការសន្មត់** | ចំនួន/តម្លៃ |
|---|---|
| ក្រុមកសិករ (ក) | ៣០ នាក់ |
| ទុនសម្រាប់ទីកន្លែងធ្វើបង្ហាញ (ខ) | $៩០ |
| ការបណ្ដុះបណ្ដាលក្រុមកសិករ (គ)<br>- ឯកសារ, ការណែនាំពីបច្ចេកវិទ្យា TIP | $៣០ |
| ការបណ្ដុះបណ្ដាលក្រុមកសិករ (ឃ)<br>- អាហារសំរ៉ន់ | $៩០ |
| ទុនចូលរួមពីកសិករគំរូ (ង) | កំលាំងពលកម្ម កូនជ្រូក១ ទម្ងន់៧គក្រ និងចំណី |
| ទិវាស្រែ - អាហារសំរ៉ន់ (ច) | $២៥ |
| ទិវាស្រែ - សំភារៈ (ឆ) | $១០ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ជ)<br>- ការបណ្ដុះបណ្ដាល, ការត្រួតពិនិត្យទីកន្លែងធ្វើបង្ហាញ | $៤២ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ (ឈ) | $២៤ |
| ការចុះត្រួតពិនិត្យ-តាមដានទៅមូលដ្ឋានដោយអ្នកឯកទេស (ញ) | $២០ |
| **សរុប** | **$៣៣១** |

DRAFT

**ការសន្មត់ប្រើប្រាស់មានៈ**

ក. ក្នុង TIP មួយ មានក្រុមកសិករ (៣០នាក់) និងកសិករគំរូ ដែលមានទីកន្លែងបង្ហាញ ២ កន្លែង

ខ. ទុនសម្រាប់ធ្វើបង្ហាញអំពីការចិញ្ចឹមជ្រូកសាច់១ក្បាល មានរួមបញ្ចូលទាំងចំណីអាហារផ្សំ ៣០គក្រ=$២០ ស្នូកចំណី/ទឹក=4៧ ជញ្ជីង/ម៉ែត្រ=4៥ ថ្នាំព្យាបាល និង វ៉ាក់សាំង=4៣ ពេទ្យសត្វភូមិចុះតាមដាន (១០ដង x $១)=4១០ សរុបរួមទាំងអស់=4៤៥ ។ ទុនសម្រាប់ទីកន្លែងធ្វើបង្ហាញ១កន្លែង ៤៥ដុល្លា សម្រាប់ពីរកន្លែង $៤៥ x២ = $៩០

គ. ឯកសារបណ្តុះបណ្តាលបច្ចេកវិទ្យា មានរួមបញ្ចូលទាំងសំភារៈសម្រាប់បង្រៀន មេរៀន ការបញ្ចាំងស្លាយ និង ផ្ទាំងរូបភាពធំៗ

ឃ. ការបណ្តុះបណ្តាលក្រុមកសិករមាន ៣វគ្គ មួយវគ្គ មានរយៈពេលមួយថ្ងៃ លើកលែងតែវគ្គ ការធ្វើជីកំប៉ុស្តិ៍ មានតែ ២វគ្គទេ និងការកំណត់ចំណាត់ថ្នាក់ដី មានមួយវគ្គ

ង. ទុនចូលរួមពីកសិករមាន កូនជ្រូក ១ ក្បាល (ទម្ងន់៧គក្រ) កន្ទក់៨០គក្រ ចុងអង្ករ៥០គក្រ ស្ងួនចំណី និងកំលាំងពលកម្ម។ ផ្តល់ចំណីដែលមានប្រូតេអ៊ីនខ្ពស់ (១:១:១)=(ចំណីផ្សំ១គក្រ, កន្ទក់១, ចុងអង្ករ១) រយៈពេល ៨០ថ្ងៃ ដើម្បីអោយកើនទម្ងន់បាន ៤៥គក្រ ហើយបន្ទាប់មកផ្តល់ចំណីធម្មតារយៈពេល៣០ថ្ងៃ ដើម្បីអោយកើនទម្ងន់បាន ៦០គក្រ (ចំណីអោយស៊ីតាមចិត្ត) ។

ច. ទិវាស្រែមានកន្លះថ្ងៃមានតែម្តងក្នុងវគ្គណាមួយក្នុងចំណោមវគ្គទាំងបី និងអាចមានការចូលរួមពីកសិករនៅក្បែរៗភូមិប្រ ហែល ៤០ ទៅ ៦០នាក់ ។

ឆ. សំភារៈសម្រាប់ទិវាស្រែរួមមាន ឧឃោសនស័ព្ទ (មេក្រូ) ផ្ទាំងក្រដាសប្លាស្ទិក និងផ្ទាំងបដារូបភាពផ្សេងៗទៀត

ជ. ថវិកាឧបត្ថម្ភប្រចាំថ្ងៃសម្រាប់មន្ត្រីកសិកម្មស្រុក រួមមាន៤ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងបង្ហាញ/ការចាប់ផ្តើម/ការត្រួតពិនិត្យតាមដាន។ ចំពោះការបណ្តុះបណ្តាលសម្រាប់ ៣វគ្គ ផ្តល់អោយ ៦ថ្ងៃ និងទិវាស្រែផ្តល់អោយ ២ថ្ងៃ។

ឈ. ប្រាក់ឧបត្ថម្ភសម្រាប់ថ្លៃធ្វើដំណើរ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ១២ថ្ងៃ

ញ. មន្ទីរកសិកម្មខេត្ត- អ្នកឯកទេសជំនាញផ្តល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យ-តាមដានការបណ្តុះបណ្តាល TIP

| **ថវិកាសម្រាប់អនុវត្តន៍** | | | | |
|---|---|---|---|---|
| | ឯកតា | តម្លៃឯកតា | ចំនួនឯកតា | តម្លៃ |
| កិច្ចសន្យាអ្នកគ្រប់គ្រងស្រុក | សន្លឹក | | | |
| សៀវភៅសម្រាប់សរសេររបាយការណ៍របស់អ្នកគ្រប់គ្រងស្រុក | ក្បាល | | | |
| កិច្ចសន្យារបស់ភ្នាក់ងារពេទ្យសត្វភូមិ | សន្លឹក | | | |
| សៀវភៅសម្រាប់សរសេររបាយការណ៍ របស់ភ្នាក់ងារពេទ្យ សត្វភូមិ | ក្បាល | | | |
| **ការប្រជុំថ្នាក់ឃុំ** | | | | |
| អាហារសំរ៉ន់ | នាក់ | | | |
| សំភារៈហ៊ឹកហ៊ឺន | L.S | | | |
| **ការហ៊ឹកហ៊ឺនអ្នកលក់ចំណី** | | | | |
| សំភារៈហ៊ឹកហ៊ឺន | L.S | | | |

DRAFT

| | | | | |
|---|---|---|---|---|
| ខិត្តប័ណ្ណស្តីពីចំណេះដឹងនៃការផ្តល់ចំណីជ្រូក | ក្បាល | | | |
| អាហារសំរ៉ន់ | នាក់ | | | |
| **ទីកន្លែងធ្វើបង្ហាញ** | | | | |
| កិច្ចសន្យារបស់កសិករគំរូ | សន្លឹក | | | |
| សៀវភៅសម្រាប់សរសេររបាយការណ៍ របស់កសិករគំរូ | ក្បាល | | | |
| ចំណីបែបពាណិជ្ជកម្ម | បាវចំនុះ<br>៣០ គ.ក្រ | | | |
| ជញ្ជីងដែលអាចថ្លឹងទំងន ់១០ គ.ក្រ | គ្រឿង | | | |
| ខ្សែសម្រាប់វាស់ | ដុំ | | | |
| ស្នូក | ស្នូក | | | |
| សៀវភៅកត់ត្រា ប៊ិច | ក្បាល | | | |
| អាហារសំរ៉ន់ | នាក់/១ថ្ងៃ | | | |

## ៣.៥ ទីកន្លែងអនុវត្តន៍គម្រោង

"បទដ្ឋានអនុវត្តបច្ចេកវិទ្យា" ត្រូវបានអនុវត្តន៍យ៉ាងជោគជ័យ នៅក្នុងទីកន្លែងដែលធ្វើពិសោធន៍ចំនួនពីរក្នុងខេត្តព្រៃវែង នៅឆ្នាំ ២០០៥ ។

DRAFT

## ៤. ឧបសម្ព័ន្ធ

### *៤.១ ឧបសម្ព័ន្ធទី១. សៀវភៅរបាយការណ៍របស់អ្នកគ្រប់គ្រងស្រុក*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ការគ្រប់គ្រងជ្រូកបំប៉នមួយក្បាល** | | | | | | | | |
| **សៀវភៅរបាយការណ៍របស់អ្នកគ្រប់គ្រងស្រុក** | | | | | | | | |
| **ការប្រៀបធៀបសេដ្ឋកិច្ចនៃប្រព័ន្ធការចិញ្ចឹមជ្រូកបំប៉នតាមការកែលំអកំរិតទាប និង មធ្យម** | | | | | | | | |
| **ការវិភាគនៅចុងបញ្ចប់នៃការផ្ដល់ចំណីបែបពាណិជ្ជកម្ម** | | | | | | | | |
| | ការកែលំអកំរិតទាប | | | | ការកែលំអកំរិតមធ្យម | | | |
| | ឯកតា | តម្លៃរៀល,ឯកតា | ចំនួនឯកតា | តម្លៃ រៀល | ឯកតា | តម្លៃរៀល/ឯកតា | ចំនួនឯកតា | តម្លៃ រៀល |
| **ចំណាយអាចប្រែប្រួល** | | | | | | | | |
| កូនជ្រូក | គ.ក្រ | | | | គ.ក្រ | | | |
| ចុងអង្ករ | គ.ក្រ | | | | គ.ក្រ | | | |
| កន្ទក់ | គ.ក្រ | | | | គ.ក្រ | | | |
| ចំណីពាណិជ្ជកម្ម | គ.ក្រ | | | | គ.ក្រ | | | |
| ថ្នាំព្យាបាល | សេសេ | | | | សេសេ | | | |
| វ៉ាក់សាំង | ក្បាល | | | | ក្បាល | | | |
| | | | | | | | | |
| **ប្រាក់ចំណូល** | | | | | | | | |
| ការលក់កូនជ្រូក | គ.ក្រ | | | | គ.ក្រ | | | |
| **ផលចំណេញ ក = ប្រាក់ចំណូល - ចំណាយអាចប្រែប្រួល** | | | | | | | | |
| **តម្លៃមិនប្រែប្រួល** | | | | | | | | |
| តម្លៃស្នូក | ឯកតា | | | | ឯកតា | | | |
| **ផលចំណេញ ខ = ផលចំណេញ ក - ចំណាយមិនប្រែប្រួល** | | | | | | | | |
| **ផលចំណេញ ក ក្នុង១ថ្ងៃ** | រៀល ក្នុង ១ថ្ងៃ | | | | រៀល ក្នុង ១ថ្ងៃ | | | |

DRAFT

| ការវិភាគបច្ចេកទេសនៃប្រព័ន្ធការចិញ្ចឹមជ្រូកបំប៉នតាមការកែលំអកំរិតទាប និង មធ្យម | | | |
|---|---|---|---|
| | | ការកែលំអកំរិតទាប | ការកែលំអកំរិតមធ្យម |
| ទំងន់ចាប់ផ្តើម | គ.ក្រ | | |
| រយៈពេលលូតលាស់ | ថ្ងៃ | | |
| ទម្ងន់ចុងក្រោយ | គ.ក្រ | | |
| អត្រាលូតលាស់ជាមធ្យម | គ.ក្រ / ថ្ងៃ | | |
| ពលកម្ម | ថ្ងៃ | | |

| ការគ្រប់គ្រងជ្រូកបំប៉នមួយក្បាល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **សៀវភៅរបាយការណ៍របស់អ្នកគ្រប់គ្រងស្រុក** | | | | | | | | |
| **ការប្រៀបធៀបសេដ្ឋកិច្ចនៃប្រព័ន្ធការចិញ្ចឹមជ្រូកបំប៉នតាមការកែលំអកំរិតទាប និង មធ្យម** | | | | | | | | |
| **ការវិភាគនៅថ្ងៃទស្សនៈកិច្ចលើកទី៤** | | | | | | | | |
| | ការកែលំអកំរិតទាប | | | | ការកែលំអកំរិតមធ្យម | | | |
| | ឯកតា | តម្លៃរៀល,ឯកតា | ចំនួនឯកតា | តម្លៃ រៀល | ឯកតា | តម្លៃរៀល/ឯកតា | ចំនួនឯកតា | តម្លៃ រៀល |
| **ចំណាយអាចប្រែប្រួល** | | | | | | | | |
| កូនជ្រូក | គ.ក្រ | | | | គ.ក្រ | | | |
| ចុងអង្ករ | គ.ក្រ | | | | គ.ក្រ | | | |
| កន្ទក់ | គ.ក្រ | | | | គ.ក្រ | | | |
| ចំណីពាណិជ្ជកម្ម | គ.ក្រ | | | | គ.ក្រ | | | |
| ថ្នាំព្យាបាល | សេសេ | | | | សេសេ | | | |
| វ៉ាក់សាំង | ក្បាល | | | | ក្បាល | | | |
| | | | | | | | | |
| **ប្រាក់ចំណូល** | | | | | | | | |
| ការលក់ជ្រូក | គ.ក្រ | | | | គ.ក្រ | | | |
| **ផលចំណេញ ក = ប្រាក់ចំណូល - ចំណាយអាចប្រែប្រួល** | | | | | | | | |

DRAFT

| **តម្លៃមិនប្រែប្រួល** | | | | | | | | |
|---|---|---|---|---|---|---|---|---|
| តម្លៃស្តុក | ឯកតា | | | | ឯកតា | | | |
| **ផលចំណេញ ខ = ផលចំណេញ ក - ចំណាយមិនប្រែប្រួល** | | | | | | | | |
| **ផលចំណេញ ក ក្នុង១ថ្ងៃ** | រៀល ក្នុង ១ថ្ងៃ | | | | រៀល ក្នុង ១ថ្ងៃ | | | |

| **ការវិភាគបច្ចេកទេសនៃប្រព័ន្ធការចិញ្ចឹមជ្រូកបំប៉នតាមការកែលំអកំរិតទាប និង មធ្យម** | | | |
|---|---|---|---|
| | | ការកែលំអកំរិតទាប | ការកែលំអកំរិតមធ្យម |
| ទម្ងន់ចាប់ផ្តើម | គ.ក្រ | | |
| រយៈពេលលូតលាស់ | ថ្ងៃ | | |
| ទម្ងន់ចុងក្រោយ | គ.ក្រ | | |
| អត្រាលូតលាស់ជាមធ្យម | គ.ក្រ / ថ្ងៃ | | |
| ពលកម្ម | ថ្ងៃ | | |

| ការអង្កេតរបស់កសិករគំរូ និង កសិករដែលចូលរួម |
|---|
| អ្វីដែលធ្វើឱ្យកសិករមានចំណាប់អារម្មណ៍ដល់បច្ចេកវិទ្យានេះ ? (១-៥ប |
| តើកសិករចំនួនប៉ុន្មាននៅក្នុងមួយក្រុមដែលកំពុងចិញ្ចឹមជ្រូក? |
| ក្នុងចំណោមកសិករទាំងនេះតើមានចំនួនប៉ុន្មានដែលនឹងទទួលបច្ចេកវិទ្យានេះ? |
| អ្វីជាចំណុចខ្លាំងនៃដំណើរការផ្សព្វផ្សាយ? |
| អ្វីជាចំណុចខ្សោយនៃដំណើរការផ្សព្វផ្សាយ? |
| តើដំណើរការផ្សព្វផ្សាយអាចត្រូវបានកែលំអដោយរបៀបណា? |
| អ្វីជាចំណុចខ្លាំងនៃបច្ចេកវិទ្យានេះ? |
| អ្វីជាចំណុចខ្សោយនៃបច្ចេកវិទ្យានេះ? |
| តើបច្ចេកវិទ្យានេះអាចត្រូវបានកែលំអដោយរបៀបណា? |

DRAFT

## ៤.២ ឧបសម្ព័ន្ធទី២. របាយការណ៍ជាគ្រីះរបស់កសិករ

| | | | | |
|---|---|---|---|---|
| ការគ្រប់គ្រងជ្រូកបំប៉នមួយក្បាល | | | | |
| របាយការណ៍របស់កសិករគំរូ | | | | |
| **ឈ្មោះកសិករគំរូ** | | | | |
| ភូមិ | | | | |
| ឃុំ | | | | |
| ស្រុក | | | | |
| ខេត្ត | | | | |
| អាយុជ្រូក | | | | |
| ទម្ងន់ជ្រូក | | | | |
| ពូជជ្រូក | | | | |
| ភេទជ្រូក | | | | |
| ប្រភពជ្រូក | | | | |
| កាលបរិច្ឆេទ | ថ្ងៃ | ប្រភេទនៃការលាយចំណី | ចំណី (គ.ក្រ) | ប្រភេទថ្នាំ និង តម្លៃ |
| | ១ | | | |
| | ២ | | | |
| | ៣ | | | |
| | ៤ | | | |
| | ៥ | | | |
| | ៦ | | | |
| | ៧ | | | |
| | ទម្ងន់ជ្រូក | គ.ក្រ | | |
| | ១ | | | |
| | ២ | | | |
| | ៣ | | | |
| | ៤ | | | |
| | ៥ | | | |
| | ៦ | | | |
| | ៧ | | | |

DRAFT

| | | | | |
|---|---|---|---|---|
| | ទម្ងន់ជ្រូក | គ.ក្រ | | |

ទិន្នន័យគួរប្រមូលរហូតដល់ថ្ងៃទី៤នៃការចុះធ្វើទស្សនៈកិច្ច

| ការគ្រប់គ្រងជ្រូកបំប៉នមួយក្បាល | |
|---|---|
| របាយការណ៍របស់កសិករគំរូ | |
| ឈ្មោះចំណីបែបពាណិជ្ជកម្ម: | |
| តម្លៃចំណីបែបពាណិជ្ជកម្ម: | |
| ចំណុះប្រូតេអ៊ីននៃចំណីបែបពាណិជ្ជកម្ម: | |
| គុណភាពកន្ទក់: | |
| គុណភាពចុងអង្ករ: | |
| តម្លៃកន្ទក់: | |
| តម្លៃចុងអង្ករ: | |

| របាយការណ៍នៃការលាយចំណី | | | |
|---|---|---|---|
| ថ្ងៃលាយចំណី | ចំណីបែបពាណិជ្ជកម្ម (គ.ក្រ) | កន្ទក់ (គ.ក្រ) | ចុងអង្ករ (គ.ក្រ) |
| | ៥ | ២.៥ | ៥ |
| | ៥ | ២.៥ | ៥ |
| | ៥ | ៥ | ៥ |
| | ៥ | ៥ | ៥ |
| | ៥ | ៥ | ៥ |
| | ៥ | ៥ | ៥ |
| សរុប | ៣០ | ២៥ | ៣០ |

DRAFT

### *៤.៣ ឧបសម្ព័ន្ធទី៣ របាយការណ៍របស់ភ្នាក់ងារពេទ្យសត្វភូមិ*

| ការគ្រប់គ្រងជ្រូកបំប៉នមួយក្បាល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| របាយការណ៍របស់ភ្នាក់ងារពេទ្យសត្វភូមិ | | | | | | | | |
| ការព្យាបាលកូនជ្រូក | | | | | | | | |
| ឈ្មោះកសិករគំរូ | | | | | | | | |
| ថ្ងៃ | ឈ្មោះ កសិករ | សត្វ (មេជ្រូក រឺ កូនជ្រូក) | បញ្ហា | ប្រភេទថ្នាំ | ចំនួនថ្នាំ (សេសេ) | តម្លៃថ្នាំ (សេសេ) | តម្លៃសេវា (រៀល) | តម្លៃ (សរុប) |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

DRAFT

## ៤.៤ ឧបសម្ព័ន្ធទី៤ ខិត្តប័ណ្ណសម្រាប់ការយល់ដឹងអំពីការផ្តល់ចំណីដល់មេជ្រូក

**ផ្តល់ចំណីដល់កូនជ្រូករបស់អ្នកដែលមានគុណភាពល្អនឹងបានផលចំណេញខ្ពស់**









**ទិញចំណីជ្រូកបែបពាណិជ្ជកម្មដែលមានប្រូតេអ៊ីនមានចំនួន ៣០ គ.ក្រ ក្នុង១បាវ**

លាយ១០គ.ក្រនៃចំណីខាងលើនេះជាមួយ១០ គ.ក្រ នៃចុងអង្ករ និង ៥ គ.ក្រ នៃកន្ទក់ ។ ផ្តល់ចំណីនេះដល់កូនជ្រូកបន្ទាប់ពីទិញវា ។

នៅពេលចំណីលាយនេះជិតអស់ លាយ២០ គ.ក្រ នៃចំណីពាណិជ្ជកម្មដែលនៅសេសសល់ជាមួយ២០ គ.ក្រ នៃកន្ទក់ និង ២០ គ.ក្រ នៃចុងអង្ករ ។ បន្ទាប់ពីនេះ ផ្តល់ចំណីតាមបែបបុរាណដល់ជ្រូក ។

ផ្តល់ចំណី និង ទឹកឱ្យបានគ្រប់គ្រាន់ដល់ជ្រូក ។

**នៅក្រោមលក្ខខណ្ឌទាំងនេះ ជ្រូកអាចកើនទម្ងន់ដល់ ៧០ គ.ក្រ ក្នុងរយៈពេល ៥ខែ និង មានសាច់ច្រើនជាង ជ្រូកដែលផ្តល់ចំណីតាមបែបបុរាណ ។**

**អ្នកអាចទទួលផលចំណេញច្រើនពីការទិញចំណីពាណិជ្ជកម្ម**

## *៤.៥ ឧបសម្ព័ន្ធទី៥ តារាងវាយតម្លៃទម្ងន់ជ្រូក*

| តារាងទម្ងន់ជ្រូក | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ប្រវែងទទឹងជ្រូក(ស.ម) | ទម្ងន់ជ្រូក (គ.ក្រ) | ប្រវែងទទឹងជ្រូក(ស.ម) | ទម្ងន់ជ្រូក (គ.ក្រ) | ប្រវែងទទឹងជ្រូក(ស.ម) | ទម្ងន់ជ្រូក (គ.ក្រ) | ប្រវែងទទឹងជ្រូក(ស.ម) | ទម្ងន់ជ្រូក (គ.ក្រ) | ប្រវែងទទឹងជ្រូក(ស.ម) | ទម្ងន់ជ្រូក (គ.ក្រ) |
| ៦០ = | ២៣ | ៧៤ = | ៤១ | ៨៩ = | ៦២ | ១០៣ = | ៩០ | ១១៧ = | ១២៩ |
| ៦១ = | ២៤ | ៧៥ = | ៤២ | ៩០ = | ៦៤ | ១០៤ = | ៩២ | ១១៨ = | ១៣២ |
| ៦២ = | ២៥ | ៧៦ = | ៤៣ | ៩១ = | ៦៦ | ១០៥ = | ៩៥ | ១១៩ = | ១៣៥ |
| ៦៣ = | ២៦ | ៧៧ = | ៤៤ | ៩២ = | ៦៨ | ១០៦ = | ៩៨ | ១២០ = | ១៣៨ |
| ៦៤ = | ២៧ | ៧៨ = | ៤៥ | ៩៣ = | ៧០ | ១០៧ = | ១០០ | ១២១ = | ១៤១ |
| ៦៥ = | ២៨ | ៧៩ = | ៤៦ | ៩៤ = | ៧២ | ១០៨ = | ១០៣ | ១២២ = | ១៤៤ |
| ៦៦ = | ២៩ | ៨០ = | ៤៧ | ៩៥ = | ៧៤ | ១០៩ = | ១០៦ | ១២៣ = | ១៤៧ |
| ៦៧ = | ៣០ | ៨១ = | ៤៨ | ៩៦ = | ៧៦ | ១១០ = | ១០៨ | ១២៤ = | ១៥០ |
| ៦៨ = | ៣១ | ៨២ = | ៥០ | ៩៧ = | ៧៨ | ១១១ = | ១១១ | ១២៥ = | ១៥៣ |
| ៦៩ = | ៣២ | ៨៣ = | ៥២ | ៩៨ = | ៨០ | ១១២ = | ១១៤ | ១២៦ = | ១៥៦ |
| ៧០ = | ៣៤ | ៨៤ = | ៥៤ | ៩៩ = | ៨២ | ១១៣ = | ១១៧ | ១២៧ = | ១៥៩ |
| ៧១ = | ៣៦ | ៨៥ = | ៥៥ | ១០០ = | ៨៤ | ១១៤ = | ១២០ | ១២៨ = | ១៦២ |
| ៧២ = | ៣៨ | ៨៦ = | ៥៧ | ១០១ = | ៨៦ | ១១៥ = | ១២៣ | ១២៩ = | ១៦៥ |
| ៧៣ = | ៤០ | ៨៧ = | ៥៨ | ១០២ = | ៨៨ | ១១៦ = | ១២៦ | ១៣០ = | ១៦៨ |

DRAFT